ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល

# ក្របខណ្ឌវាយតម្លៃសំណើគម្រោង
# បច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍

រៀបចំដោយ
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល

២០២២

# អារម្ភកថា

បច្ចេកវិទ្យាឌីជីថល មានសក្ដានុពលខ្ពស់ ក្នុងការចូលរួមចំណែកគាំទ្រ និងជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព, បរិយាបន្ន និង ភាពធន់ តាមរយៈការបង្កើតប្រភពកំណើនថ្មី, ការលើកកម្ពស់ផលិតភាព និងប្រសិទ្ធភាពនៃគ្រប់វិស័យ ព្រមទាំងការផ្ដល់ជម្រើសដំណោះស្រាយ ឬមធ្យោបាយថ្មីប្រកបដោយនវានុវត្តន៍ ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមសកល ដែលបាន និងកំពុងកើតមានឡើងជាបន្តបន្ទាប់ ដូចជាវិបត្តិនៃជំងឺកូវីដ-១៩ និង ការប្រែប្រួលអាកាសធាតុ ជាដើម ។ ទោះជាយ៉ាងនេះក្ដី, ការវិវឌ្ឍយ៉ាងលឿននៃបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី ៤.០ អាចបង្កើតឱ្យមានគម្លាតនៃឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថល ដែលការណ៍នេះ អាចធ្វើឱ្យគម្លាតអភិវឌ្ឍន៍កាន់តែរីកធំឡើង ជាពិសេសរវាងប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍន៍ ។

នៅក្នុងនិន្នាការសកលនាពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត, ឌីជីថលូបនីយកម្ម និង បរិវត្តកម្មឌីជីថល នឹងក្លាយជាកត្តាចម្បងមួយ ដែលកំណត់ភាពប្រកួតប្រជែង នៅក្នុងទីផ្សារអន្តរជាតិ ក៏ដូចជាភាពជោគជ័យនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច នៃប្រទេសនីមួយៗ ។ រាជរដ្ឋាភិបាលកម្ពុជា យល់ច្បាស់អំពីនិន្នាការនេះ និងបាន និងកំពុងរៀបចំបទដ្ឋានគតិយុត្ត និង ក្របខណ្ឌគោលនយោបាយ ជាបន្តបន្ទាប់ ជាពិសេស ការដាក់ឱ្យអនុវត្ត **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** និង **គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥** ដើម្បីជំរុញការអភិវឌ្ឍវិស័យឌីជីថល ក្នុងគោលដៅធានាភាពប្រកួតប្រជែង, ពង្រឹងពិពិធកម្មសេដ្ឋកិច្ច និងលើកកម្ពស់ភាពធន់ របស់កម្ពុជា ។

ស្របពេលជាមួយគ្នានេះ, រាជរដ្ឋាភិបាល ក៏មានភាពប្រាកដនិយម និងយល់ច្បាស់ថា ភាពជោគជ័យនៃការអភិវឌ្ឍវិស័យឌីជីថល អាស្រ័យលើប្រសិទ្ធភាពនៃការអនុវត្តជាក់ស្ដែង ជុំវិញការរៀបចំ និងអនុវត្តគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់បំផុត ស្របតាមគោលការណ៍បច្ចេកទេស, សេដ្ឋកិច្ច និង នយោបាយ ព្រមទាំងការវិភាជថវិកា ក្នុងបរិការណ៍នៃការធ្លាក់ចុះនៃធនធានហិរញ្ញវត្ថុសាធារណៈ ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាល តាមរយៈ **គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.)** សម្រេចដាក់ចេញនូវ «**ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍**» ដើម្បីជាក្របខណ្ឌរួម និងជាផែនទីចង្អុលផ្លូវ ក្នុងគោលបំណង ជំរុញការធ្វើសុខដុមនីយកម្មគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ពីគ្រប់ប្រភពហិរញ្ញប្បទាន និងគ្រប់កម្រិតរដ្ឋបាលដោយធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃចំណាយសាធារណៈ តាមរយៈការវិនិយោគចំគោលដៅ ឆ្លើយតបនឹងតម្រូវការជាអាទិភាព ទៅតាមលទ្ធភាពជាក់ស្ដែងនៃថវិកា និងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលរឹងមាំ មានសុវត្ថិភាព និងមានស្ថិរភាពខ្ពស់ដើម្បីចូលរួមចំណែកក្នុងការជំរុញ និងពន្លឿនការកសាង និងអភិវឌ្ឍរដ្ឋាភិបាល, សេដ្ឋកិច្ច, ធុរកិច្ច និងសង្គមឌីជីថល ប្រកបដោយចីរភាព និងបរិយាបន្ន ។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ក្នុងនាមជាប្រធាននៃ **គ.ស.ធ.ឌ.**, ខ្ញុំសូមគោរពសម្តែងកតញ្ញូតាធម៌ និងកតវេទិតាធម៌យ៉ាងជ្រាល-ជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែផ្តល់អនុសាសន៍ និងការតម្រង់ទិសដ៏ខ្ពង់ខ្ពស់បំផុតចំពោះការកសាង និង ការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមឌីជីថលនៅកម្ពុជា។

ជាទីបញ្ចប់, ខ្ញុំសូមថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះឯកឧត្តមបណ្ឌិត **គង់ ម៉ារី** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** និង ថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** ដែលបានខិតខំប្រឹងប្រែងរៀបចំក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍នេះរហូតសម្រេចជាស្ថាពរ។ ទន្ទឹមនេះ, ខ្ញុំក៏សូមលើកទឹកចិត្តឱ្យក្រសួង-ស្ថាប័ន និង ក្រុមការងារពាក់ព័ន្ធទាំងអស់ចូលរួមអនុវត្តក្របខណ្ឌវាយតម្លៃនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីជំរុញការអភិវឌ្ឍវិស័យឌីជីថលនៅកម្ពុជា និងចូលរួមចំណែក ក្នុងការឈានឆ្ពោះទៅសម្រេចឱ្យបាននូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព, បរិយាបន្ន និង ភាពធន់ ។

*ថ្ងៃ អង្គារ ១៤ រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*

*រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

**អារម្ភកថា** ........ i
**១. សេចក្តីផ្តើម** ........ ១
១.១. សារបាន ........ ១
១.២. សនិទានកម្ម ........ ២
**២. ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍** ........ ៤
២.១. គោលបំណង និង គោលដៅ ........ ៤
២.២. គោលការណ៍នៃការវាយតម្លៃ ........ ៤
២.២.១. គោលការណ៍រួម ........ ៥
២.២.២. គោលការណ៍ជាក់លាក់ ........ ១៣
២.៣. អភិក្រមនៃការវាយតម្លៃ ........ ១៧
**៣. យន្តការនៃការវាយតម្លៃ** ........ ១៨
៣.១. វិសាលភាពនៃការវាយតម្លៃ ........ ១៨
៣.២. យន្តការសម្របសម្រួល ........ ២០
៣.៣. ការបែងចែកតួនាទី និងភារកិច្ច ........ ២១
៣.៣.១. ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ........ ២១
៣.៣.២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ........ ២១
៣.៣.៣. ក្រុមការងារចម្រុះ ........ ២២
**៤. ការគ្រប់គ្រង និង តាមដានការវាយតម្លៃ និងការអនុវត្តគម្រោង** ........ ២២
**ឧបសម្ព័ន្ធទី ១ ៖ ការដាក់ពិន្ទុសំណើគម្រោង** ........ ២៥
**ឧបសម្ព័ន្ធទី ២ ៖ វាក្យសព្ទបច្ចេកទេស** ........ ២៨

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

## ១. សេចក្តីផ្តើម

### ១.១. សារបាន

ក្នុងរយៈពេលជាងពីរទសវត្សរ៍ មុនការឆ្លងរាលដាលនៃជំងឺកូវីដ-១៩, កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាបន្ន ក្នុងរង្វង់ជាង ៧% ក្នុងមួយឆ្នាំ ប៉ុន្តែជំងឺកូវីដ-១៩ បានបន្ទចំបង្អាក់ និងដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរមកលើការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងបានផ្តល់ផលប៉ះពាល់ដល់ជីវភាព, សុខភាព និងអាយុជីវិត របស់ប្រជាជនកម្ពុជា ។ ទោះជាយ៉ាងនេះក្តី, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ប្រកបដោយស្មារតីបុរេសកម្ម និងការទទួលខុសត្រូវខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, រាជរដ្ឋាភិបាលកម្ពុជាបានក្លាយជាប្រទេសឈានមុខមួយនៅលើសកលលោក ដែលអាចគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង ស្តារ និងជំរុញកំណើនសង្គម-សេដ្ឋកិច្ចឡើងវិញ បានយ៉ាងល្អប្រសើរ ។

ថ្វីត្បិតមានការថមថយ, ប៉ុន្តែជំងឺកូវីដ-១៩ បានបន្សល់ទុកនូវស្លាកស្នាមយូរអង្វែង និងបង្កឱ្យមានការផ្លាស់ប្តូររបៀបរបបរស់នៅ តាមគន្លងប្រក្រតីភាពថ្មី ហើយ អ្វីដែលគួរឱ្យកត់សម្គាល់បំផុតនោះគឺ ជំងឺរាតត្បាតនេះបានធ្វើឱ្យមានការកើនឡើងកាន់តែខ្លាំងនៃការធ្វើបរិវត្តឌីជីថល ទាំងក្នុងវិស័យឯកជន និងសាធារណៈក្នុងល្បឿនដែលយើងមិនដែលធ្លាប់រំពឹងទុក ដើម្បីឆ្លើយតបទៅនឹងការកាត់បន្ថយទំនាក់ទំនងផ្ទាល់ និងតម្រូវការធ្វើដំណើរ ។ ការណ៍នេះ បានបង្កើតជាកាលានុវត្តភាពថ្មីមួយសម្រាប់កម្ពុជា ក្នុងការជំរុញការអភិវឌ្ឍវិស័យឌីជីថល ដែលជាវិស័យគន្លឹះ និងមានសក្តានុពលខ្ពស់ ក្នុងការជួយលើកកម្ពស់ភាពប្រកួតប្រជែង និង ការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា សំដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព, បរិយាបន្ន និង ភាពរឹងមាំ និងឈានឆ្ពោះទៅរកការសម្រេចបាននូវចក្ខុវិស័យប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅត្រឹមឆ្នាំ ២០៣០ និង ប្រទេសដែលមានចំណូលខ្ពស់ នៅត្រឹមឆ្នាំ ២០៥០ ។

ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ការអភិវឌ្ឍវិស័យឌីជីថលជារបៀបវារៈគោលនយោបាយដ៏ចម្បងមួយ និងបានដាក់ចេញនូវ **«ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥»** និង **«គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥»** សំដៅជំរុញ និងពន្លឿនការកសាងរដ្ឋាភិបាល, សេដ្ឋកិច្ច, ធុរកិច្ច និងសង្គមឌីជីថល ដោយមានការដាក់ចេញនូវវិធានការមុតស្រួចរយៈពេលខ្លី, មធ្យម និង វែង ។ ការសម្រេចបាននូវការអនុវត្តក្របខណ្ឌគោលនយោបាយនេះដោយជោគជ័យតម្រូវឱ្យមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗនៅតាមក្រសួងស្ថាប័នទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ឆ្លើយតបទៅនឹងការកសាងរដ្ឋាភិបាលឌីជីថល, សេដ្ឋកិច្ច និង ធុរកិច្ច ក៏ដូចជាសង្គមឌីជីថលទាំងមូលផងដែរ ។ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការនេះ និងដើម្បីជួយគាំទ្រដល់ដំណើការនៃការពិនិត្យគម្រោង ធានាបាននូវភាពត្រឹមត្រូវទាំងទិដ្ឋភាពបច្ចេកទេស និងគោលនយោបាយ, ការបង្កើតក្របខណ្ឌវាយតម្លៃសំណើគម្រោងមួយ ដែលគ្រប់ជ្រុងជ្រោយ ដើម្បីបម្រើជាធាតុចូល ដល់ការធ្វើវិភាគថវិកា ឱ្យចំគោលដៅ និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាពិសេសក្នុងបរិការណ៍ដែលកម្ពុជា ក៏ដូចជាសកល

លោកទាំងមូលបាន និងកំពុងជួបប្រទះនូវភាពខ្វះខាតនៃប្រភពហិរញ្ញវត្ថុសាធារណៈ មានភាពចាំបាច់ដែលត្រូវគិតគូរនិងរៀបចំតាំងពីដើមគ្រានៃការអនុវត្តក្របខណ្ឌគោលនយោបាយនេះ។

## ១.២. សនិទានកម្ម

យោងតាមរបាយការណ៍សិក្សាអំពីស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា, ក្រសួង-ស្ថាប័នចំនួន ២៨ មានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានចំនួនសរុប ១៨២ ។ ទោះបីជា គម្រោងហាក់មានចំនួនច្រើនគួរឱ្យកត់សម្គាល់, ជាក់ស្តែងគម្រោងភាគច្រើនជាគម្រោងតូចៗដែលគ្រាន់តែបម្រើការងារបន្ទាន់ និង តម្រូវការជាក់ស្តែងនៅតាមនាយកដ្ឋាន ឬអង្គភាពក្រោមឱវាទនានា របស់ក្រសួង-ស្ថាប័នតែប៉ុណ្ណោះ។ យ៉ាងណាមិញ, គម្រោងដែលមានចរិតជាការកសាងទិន្នន័យគោល (Base registry) នៅមិនទាន់បានកសាងពេញលេញនៅឡើយ និងគុណភាពនៃទិន្នន័យក៏នៅមានកម្រិត។ ទោះជាយ៉ាងណាក៏ដោយ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួន ១៦៧ ត្រូវបានរាយការណ៍ថាកំពុងត្រូវបានប្រើប្រាស់ និងដំណើរការ ខណៈដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួន ២ លែងដំណើរការ ដូចមានបង្ហាញក្នុងតារាងទី ១ ខាងក្រោម ។

**តារាងទី ១ ៖ ស្ថានភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅតាមក្រសួង-ស្ថាប័ន**

| ស្ថានភាព | ចំនួនប្រព័ន្ធ | ភាគរយ |
|---|---|---|
| កំពុងប្រើប្រាស់ | ១៦៧ | ៩១,៧៥ % |
| ឈប់ប្រើប្រាស់ | ២ | ១,០៩ % |
| កំពុងអភិវឌ្ឍ | ៧ | ៣,៨៤ % |
| កំពុងសាកល្បង | ៦ | ៣,២៩ % |
| **សរុប** | **១៨២** | **១០០ %** |

*ប្រភព៖ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥*

របាយការណ៍ខាងលើនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីទិដ្ឋភាពជាក់ស្តែង ក្នុងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលជាទូទៅជួបប្រទះនូវបញ្ហាប្រឈម ដូចខាងក្រោម ៖

- **ការបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដាច់ដោយឡែកពីគ្នា និងមានភាពត្រួតស៊ីគ្នា** ៖ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្ទើរតែទាំងអស់ត្រូវបានបង្កើតឡើង សម្រាប់ជួយសម្រួលការងារនៃអង្គភាពនីមួយៗ ដោយមិនបានគិតគូរពីការតភ្ជាប់អន្តរប្រតិបត្តិការ ឬការចែករំលែកធនធានជាមួយគ្នា ទោះបីស្ថិតក្នុងក្របខណ្ឌចំណុះឱ្យក្រសួង-ស្ថាប័នតែមួយក៏ដោយ ។ ម្យ៉ាងវិញទៀត, ប្រព័ន្ធគាំទ្រដល់ការគ្រប់គ្រងរដ្ឋបាល ជាពិសេសការគ្រប់គ្រងធនធានមនុស្ស និង ឯកសារ ក៏ត្រូវបានបង្កើតឡើងត្រួតស៊ីគ្នា ទោះបីស្ថិតក្នុងអង្គភាពចំណុះឱ្យក្រសួង-ស្ថាប័នតែមួយ ។ កត្តាទាំងនេះ

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

កើតឡើង ដោយសារកង្វះផែនការរួម ដែលដាក់ចេញនូវទិសដៅ និងយុទ្ធសាស្ត្រច្បាស់លាស់ ដល់អង្គភាពក្រោមបង្គាប់ ក្នុងការរៀបចំគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

- **ភាពជាម្ចាស់លើកូដនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ៖** ក្នុងចំណោមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រមាណ ២៨% ដែលបានរៀបចំរួចរាល់, ក្រសួង-ស្ថាប័ន មិនមានភាពជាម្ចាស់ពេញលេញ និងមិនមានលទ្ធភាពកែសម្រួលកូដដោយខ្លួនឯង ដោយសារភាគច្រើនជាប្រព័ន្ធ ដែលបានទិញពីក្រុមហ៊ុនផ្តល់សេវាកម្មព័ត៌មានវិទ្យា ឬ ជាជំនួយរបស់ដៃគូអភិវឌ្ឍន៍ ដែលផ្តល់លទ្ធភាពតិចតួចបំផុត ក្នុងការទទួលបានសិទ្ធិ ក្នុងការកែប្រែកូដ នៅពេលគម្រោងត្រូវបានបញ្ចប់ ។ កង្វះភាពជាម្ចាស់នេះ បានបង្កជាផលលំបាក ក្នុងការថែទាំ និងកែសម្រួលមុខងារប្រព័ន្ធ ឬ ភ្ជាប់ទំនាក់ទំនងអន្តរប្រតិបត្តិការ ជាមួយប្រព័ន្ធដទៃទៀត ។
- **ភាពជាម្ចាស់លើទិន្នន័យ ៖** ក្នុងចំណោមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានប្រមាណ ៣០%, ក្រសួង-ស្ថាប័នមិនមានលទ្ធភាព ក្នុងការគ្រប់គ្រងទិន្នន័យ ដោយប្រព័ន្ធទិន្នន័យ ត្រូវបានគ្រប់គ្រងដោយវិស័យឯកជន ឬ ដៃគូអភិវឌ្ឍន៍ ។
- **ចំណាយខ្ពស់ទៅលើអាជ្ញាបណ្ណ ៖** ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួន មានតម្រូវការចំណាយខ្ពស់ ដោយសារការប្រើប្រាស់សុស្វវែ (software) ដែលមានថ្លៃខ្ពស់ ដោយមិនបានសិក្សាពីសុស្វវែជំនួស ដែលមានលក្ខណៈបើកចំហ ហើយផ្តល់លទ្ធផលប្រហាក់ប្រហែលគ្នា ជាពិសេស ផ្តល់លទ្ធភាពក្នុងការកែប្រែកូដ ដោយមិនចាំបាច់ទិញអាជ្ញាបណ្ណ ។ បញ្ហានេះអាចធ្វើឱ្យប៉ះពាល់ដល់និរន្តរភាពថវិការបស់គម្រោង ដែលអនុវត្ត ។
- **កង្វះខាតភាពរួចរាល់ ក្នុងការចាប់យកឌីជីថល ៖** លទ្ធភាពនៃការចាប់យកឌីជីថលរបស់ក្រសួង-ស្ថាប័ន, អង្គភាពចំណុះ និងអ្នកប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មានកម្រិតខុសៗគ្នា ។ ក្នុងន័យនេះ, ប្រសិនបើក្រសួង-ស្ថាប័ន រៀបចំគម្រោងបច្ចេកវិទ្យាព័ត៌មាន ដោយមិនបានសិក្សាឱ្យបានច្បាស់ពីភាពរួចរាល់ ក្នុងការចាប់យកឌីជីថលនោះទេ, ការរៀបចំគម្រោង នឹងធ្វើឱ្យខាតបង់ធនធាន ដោយសារក្រសួង-ស្ថាប័ន, អង្គភាពចំណុះ និងអ្នកប្រើប្រាស់ ពុំអាចប្រើប្រាស់ និងទាញយកអត្ថប្រយោជន៍ឱ្យអស់លទ្ធភាព ពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

បន្ថែមលើបញ្ហាបច្ចេកទេស, ការលើកសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ប្រចាំឆ្នាំមានលក្ខណៈដាច់ដោយឡែកពីគ្នារៀងៗខ្លួន ហើយការកត់ត្រាចំណាយពីគ្រប់ប្រភពហិរញ្ញប្បទាន និងគ្រប់កម្រិតរដ្ឋបាលស្ថិតក្នុងមាតិកាចំណាត់ថ្នាក់ចំណាយផ្សេងៗគ្នាដែលការណ៍នេះ ធ្វើឱ្យប្រសិទ្ធភាពនៃការវិភាជថវិកានៅមានកម្រិត ហើយការតាមដានប្រសិទ្ធភាពចំណាយ និង វិនិយោគទៅលើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ នេះក៏មានភាពលំបាកផងដែរ។

ដើម្បីបញ្ចៀសឱ្យបាននូវបញ្ហាប្រឈមខាងលើ ព្រមទាំងឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដូចបានបញ្ជាក់ខាងលើ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបង្កើតក្រុមការងារអន្តរក្រសួងមួយតាមរយៈ "សេចក្តីសម្រេចស្តី-

ពីការបង្កើតក្រុមការងារអន្តរក្រសួងសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍" ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០២០ ដែលជាយន្តការបណ្តោះអាសន្នសម្រាប់ជួយសម្រួល និងគាំទ្រដល់ការងារនេះ។ ក្រោយពីការដាក់ចេញនូវក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល, រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយន្តការដឹកនាំសម្របសម្រួលថ្មីដែលមានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និង គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ជាសេនាធិការបច្ចេកទេស។ តាមរយៈយន្តការថ្មីនេះ, គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ដែលមានសមត្ថកិច្ចដឹកនាំសម្របសម្រួលការងារផែនសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល បានរៀបចំដាក់ចេញនូវ **«ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍»** ដើម្បីធ្វើជាក្របខណ្ឌរួមមួយ និងជាមូលដ្ឋានដ៏មានសារៈសំខាន់ ដល់ការងារពិនិត្យ និងវាយតម្លៃសំណើគម្រោង ជំនួសឱ្យយន្តការបណ្តោះអាសន្ន ហើយឯកសារនេះជា **ឯកសាររស់** ដោយត្រូវមានការធ្វើបច្ចុប្បន្នភាព ក្នុងករណីចាំបាច់ ដើម្បីឱ្យស្របតាមការវិវត្តយ៉ាងលឿននៃវិស័យឌីជីថលផងដែរ ។

## ២. ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

### ២.១. គោលបំណង និង គោលដៅ

ការដាក់ចេញនូវ **ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍** មានគោលបំណងជំរុញការធ្វើសុខដុមនីយកម្មគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ពីគ្រប់ប្រភពហិរញ្ញប្បទាន និងគ្រប់កម្រិតរដ្ឋបាលដោយធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃចំណាយសាធារណៈតាមរយៈការវិនិយោគចំគោលដៅឆ្លើយតបនឹងតម្រូវការជាអាទិភាពទៅតាមលទ្ធភាពជាក់ស្តែងនៃថវិកា និង ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលរឹងមាំ មានសុវត្ថិភាព និងមានស្ថិរភាពខ្ពស់ដើម្បីចូលរួមចំណែកក្នុងការជំរុញ និងពន្លឿនការកសាង និងអភិវឌ្ឍរដ្ឋាភិបាល, សេដ្ឋកិច្ច, ធុរកិច្ច និងសង្គមឌីជីថល ប្រកបដោយចីរភាព និង បរិយាបន្នស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា២០២១-២០៣៥ និង គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ព្រមទាំងគ្រប់គោលនយោបាយនានារបស់រាជរដ្ឋាភិបាលក្នុងវិស័យឌីជីថល ។

ដើម្បីសម្រេចគោលបំណងខាងលើ, ក្របខណ្ឌនេះ មានគោលដៅកំណត់ឱ្យបានច្បាស់លាស់នូវគោលការណ៍ អភិក្រម និង យន្តការ នៃការវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ស្របតាមគោលការណ៍រួម និងគោលការណ៍ជាក់លាក់ដោយឆ្លុះបញ្ចាំង អំពីទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពហិរញ្ញវត្ថុគ្រប់ជ្រុងជ្រោយសម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការពិនិត្យ, អនុម័ត និងវិភាជថវិកាគ្រប់សំណើគម្រោងដែលមានគុណភាព និង លក្ខណៈសម្បត្តិគ្រប់គ្រាន់។

### ២.២. គោលការណ៍នៃការវាយតម្លៃ

ការរៀបចំគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព និង គណនេយ្យភាព ត្រូវស្របតាមគោលការណ៍រួម និងគោលការណ៍ជាក់លាក់ ។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

### ២.២.១. គោលការណ៍រួម

គ្រប់សំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ត្រូវគោរពតាមគោលការណ៍រួមចំនួន ១១ ដែលក្នុងនោះគោលការណ៍ជ្រើសរើស និងធ្វើថវិកានីយកម្មគម្រោងមានចំនួន ៦ ដែលអនុលោមតាមអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ និងគោលការណ៍គោលនយោបាយចំនួន៥ ដែលបានកំណត់ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។

❖ **គោលការណ៍ជ្រើសរើស និង ធ្វើថវិកានីយកម្មគម្រោង**

អនុលោមតាមអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ, គ្រប់សំណើគម្រោងត្រូវគោរពគោលការណ៍រួមចំនួន ៦ ចំណុចដូចខាងក្រោម៖

១). **គោលការណ៍សនិទានកម្ម ៖** គម្រោងត្រូវតែមានភាពចាំបាច់ ចំពោះការធ្វើបរិវត្តកម្មឌីជីថល ដែលឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព នៃក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ព្រមទាំងគោលនយោបាយ, ផែនការយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀតរបស់រាជរដ្ឋាភិបាល;

២). **គោលការណ៍ផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៖** គម្រោងត្រូវតែបង្ហាញអំពីផលចំណេញផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលទទួលបានពីការវិនិយោគ ដើម្បីរួមចំណែកដល់ការកសាង និងអភិវឌ្ឍរដ្ឋាភិបាល, សេដ្ឋកិច្ច, ធុរកិច្ច និងសង្គមឌីជីថល ។ ដោយឡែក, សម្រាប់គម្រោង ដោយប្រភពហិរញ្ញប្បទានចម្រុះ ត្រូវមានភាពទន់ភ្លន់ ចំពោះការអនុវត្តគោលការណ៍ផលសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះ ដើម្បីធានា និងលើកកម្ពស់ភាពទាក់ទាញទុនវិនិយោគបន្ថែមពីវិស័យឯកជនសម្រាប់បំពេញតម្រូវការវិនិយោគសាធារណៈសរុប ព្រមទាំងឆ្លើយតបទៅនឹងបុព្វហេតុកសាង និងអភិវឌ្ឍរដ្ឋាភិបាល, សេដ្ឋកិច្ច, ធុរកិច្ច និងសង្គមឌីជីថល ប្រកបដោយចីរភាព និងបរិយាបន្ន;

៣). **គោលការណ៍ជម្រើសប្រសើរបំផុត ៖** គម្រោងត្រូវមានឧត្តមភាពប្រៀបធៀប និងផលសេដ្ឋកិច្ច និងសង្គមឌីជីថលខ្ពស់ជាងគេ ធៀបនឹងជម្រើសគម្រោងដទៃផ្សេងទៀត;

៤). **គោលការណ៍ភាពអាចទ្រទ្រង់បាននៃថវិកា៖** តម្រូវការថវិកា សម្រាប់ចំណាយលើវិនិយោគ ប្រតិបត្តិការ និងថែទាំ ត្រូវស្ថិតនៅក្នុងភាពអាចទ្រទ្រង់បាននៃថវិកា និងត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម, ក្របខណ្ឌថវិការយៈពេលមធ្យម, ផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ;

៥). **គោលការណ៍ភាពអាចអនុវត្តបាន ៖** សមាសភាគគម្រោង, អភិក្រម, យន្តការ និងរចនាសម្ព័ន្ធ ព្រមទាំងសមត្ថភាពស្ថាប័ន សម្រាប់ការគ្រប់គ្រង និងអនុវត្តគម្រោង ត្រូវឆ្លើយតបនឹងតម្រូវការ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា; និង

៦). **គោលការណ៍ភាពរួចរាល់ សម្រាប់ការចាប់ផ្តើមអនុវត្តគម្រោង ៖** ឯកសារណែនាំស្តីពីការគ្រប់គ្រងការអនុវត្តគម្រោង, ផែនការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, ផែនការ

គ្រប់គ្រងបរិស្ថាន, ផែនការលទ្ធកម្មគម្រោង, ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ព្រមទាំងលក្ខខណ្ឌចាំបាច់នានា ត្រូវរៀបចំឱ្យបានមុនពេលគម្រោងត្រូវបានអនុម័ត ។




**រូបភាពទី ១ ៖ គោលការណ៍រួមនៃការជ្រើសរើស និងការធ្វើថវិកានីយកម្មគម្រោង**

❖ **គោលការណ៍គោលនយោបាយ**

ការរៀបចំសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព និង គណនេយ្យភាពត្រូវស្របតាមគោលការណ៍គោលនយោបាយដូចបានកំណត់ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២២-២០៣៥ និងគោលនយោបាយពាក់ព័ន្ធនានាក្នុងលំហឌីជីថល។ ក្នុងន័យនេះ គម្រោងត្រូវគោរពគោលការណ៍រួមនៃគោលការណ៍គោលនយោបាយចំនួន៥ បន្ថែមទៀតដូចខាងក្រោម៖

១). **គោលការណ៍បញ្ចូលទិន្នន័យតែមួយលើក** (The Once-Only Principle) ៖ គឺជាគោលការណ៍អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឌីជីថល ដែលតម្រូវឱ្យក្រសួង-ស្ថាប័ន, នីតិបុគ្គល និងប្រជាជន ផ្តល់ទិន្នន័យតែមួយលើក ដល់អាជ្ញាធរ និងក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដោយមិនស្នើសុំ ឬតម្រូវឱ្យផ្តល់ទិន្នន័យដដែលច្រើនលើកនោះទេ ។ គោលការណ៍នេះជួយកាត់បន្ថយការបញ្ចូលទិន្នន័យដែលគ្មានសង្គតិភាព និងចំណាយរដ្ឋបាល និងបន្ទុកការងាររបស់អាជ្ញាធរ និងក្រសួង-ស្ថាប័នមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធ ក្នុងការប្រមូល, រក្សាទុក និងប្រើប្រាស់ទិន្នន័យ ។

២). **គោលការណ៍អន្តរប្រតិបត្តិការជាប្រព័ន្ធអេកូឡូស៊ីតែមួយ** (Interoperability as an Ecosystem Principle) ៖ គោលការណ៍នេះធានាថា គ្រប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងអស់របស់រាជរដ្ឋាភិបាលអាចមានប្រតិបត្តិការឯករាជ្យ និងអាចធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធដទៃទៀត

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

ប្រកបដោយសុវត្ថិភាព ជាប្រព័ន្ធអេកូឡូស៊ីមួយ ដើម្បីបំពេញមុខងារឱ្យគ្នាទៅវិញទៅមក ក្នុងការបម្រើសេវាសាធារណៈឱ្យមានប្រសិទ្ធភាព ។ ក្នុងន័យនេះ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលបានប្រើប្រាស់ដោយក្រសួង-ស្ថាប័ន ត្រូវមានអន្តរប្រតិបត្តិការ និងការផ្លាស់ប្តូរទិន្នន័យទៅវិញទៅមក ។ ម្យ៉ាងទៀត, គោលការណ៍នេះអនុញ្ញាតឱ្យប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលអាចធ្វើអន្តរប្រតិបត្តិការ និងផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់វិស័យឯកជន ដើម្បីជំរុញនវានុវត្តន៍ និងអភិបាលកិច្ចទិន្នន័យ ក្នុងន័យបង្កើនប្រសិទ្ធភាពប្រតិបត្តិការអាជីវកម្មរបស់វិស័យឯកជន ។

៣). **គោលការណ៍ផ្តួចផ្តើម និង ពង្រីកដើម្បីប្រសិទ្ធផល** (Land and Expand for Efficiency Principle) ៖ គោលការណ៍នេះបើកលទ្ធភាពដល់ក្រសួង-ស្ថាប័ន ក្នុងការផ្តួចផ្តើមរៀបចំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយចាប់ផ្តើមពីតូច និង ពង្រីកទៅធំ សម្រាប់បំពេញតម្រូវការ ក្នុងការគ្រប់គ្រង និង ផ្តល់សេវាសាធារណៈរបស់ខ្លួន ប្រកបដោយប្រសិទ្ធផល ឈរលើមូលដ្ឋាន និង ក្របខណ្ឌកំណត់ជាក់លាក់មួយ និង ស្របតាមគោលការណ៍ទាំង ២ ខាងលើ។ ក្នុងន័យនេះ, ការផ្តួចផ្តើមរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវផ្តោតលើចំណុចអាទិភាពចាំបាច់ និងប្រសិទ្ធផលជាគន្លឹះ ទើបអាចពង្រីកវិសាលភាព តាមរយៈការប្រើប្រាស់សមាសធាតុ ដែលមានស្រាប់ (Reusability) ឬ ពង្រីកបន្ថែម ដើម្បីចែករំលែកការប្រើប្រាស់ជាមួយប្រព័ន្ធផ្សេងៗ ដោយធានាបាននូវប្រសិទ្ធផល និង សន្តិសុខនៃប្រព័ន្ធទាំងមូល ។

៤). **គោលការណ៍វិមជ្ឈការកូនកាត់** (Hybrid Decentralized)៖ ការផ្តល់ឯករាជ្យភាពនៃការគ្រប់គ្រងធនធាន និង កម្មសិទ្ធិនៃការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រូវផ្អែកលើការកំណត់ទិន្នន័យគោល (Base registry)។ យោងតាមអនុក្រឹត្យស្តីពីការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា, ទិន្នន័យគោលសំដៅដល់ទិន្នន័យមូលដ្ឋានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចដែលជាម្ចាស់ទិន្នន័យដើម ហើយមានតែម្ចាស់ទិន្នន័យដើមទេ ដែលមានសិទ្ធិធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងនោះស្របតាមច្បាប់ និងបទប្បញ្ញត្តិ ដែលមានជាអាទិ៍៖ ទិន្នន័យមនុស្ស ទិន្នន័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ទិន្នន័យចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ទិន្នន័យធុរកិច្ចនិងសហគ្រាស ទិន្នន័យអចលនវត្ថុ ទិន្នន័យភូមិសាស្ត្រ ទិន្នន័យអប់រំ ទិន្នន័យការងារ ទិន្នន័យស្ថិតិជាតិ ទិន្នន័យយានយន្តនិងផ្លូវថ្នល់ ទិន្នន័យសុខាភិបាល ទិន្នន័យច្បាប់ ជាដើម។

៥). **គោលការណ៍ប្រើប្រាស់ធនធានរួម និងមានស្រាប់** (Resource Sharing)៖ ក្រសួង-ស្ថាប័នត្រូវគិតគូរទៅលើការប្រើប្រាស់ធនធានរួម និង មានស្រាប់ស្របតាមតម្រូវការជាក់ស្តែង និង ស្របតាមនិន្នាការបច្ចេកវិទ្យានាពេលបច្ចុប្បន្នដែលកំពុងបោះជំហានទៅរក ការប្រើប្រាស់ធនធានរួមគ្នាប្រកបទៅដោយប្រសិទ្ធភាព និង ឱ្យអស់សក្តានុពល, ចំណាយថ្លៃដើមទាប និងការកាត់បន្ថយបន្ទុករដ្ឋបាល។ បន្ថែមលើនេះ, ក្រសួង-ស្ថាប័ន ត្រូវគិតគូរប្រើប្រាស់នូវបច្ចេកវិទ្យាដែលកំពុងតែផុសផុល (mainstream) ដែលផ្អែកទៅលើស្តង់ដាបើកចំហ (Open Standard), ភាពចាស់ទុំនៃ

ការប្រើប្រាស់ (adoption maturity) និងមានសមត្ថភាពក្នុងការពន្យារភាពអាចប្រើប្រាស់បាន (usability) ដើម្បីកាត់បន្ថយការវិនិយោគជាន់គ្នា និង ភាពលើសតម្រូវការ (redundant)។ ក្នុងន័យនេះក្រសួង-ស្ថាប័នមិនត្រូវរៀបចំ ឬ វិនិយោគទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ឬ ថ្នាលឌីជីថលគ្រឹះដែលមានរួចហើយនោះទេ ប៉ុន្តែត្រូវចូលរួមប្រើប្រាស់ និងទាញយកប្រយោជន៍ជាអតិបរមានៃធនធានដែលមានស្រាប់ទាំងនោះដើម្បីកាត់បន្ថយចំណាយ និង លុបបំបាត់ការបង្កើតប្រព័ន្ធព័ត៌មានដដែលៗច្រើនដងដែលមានមុខងារជាន់គ្នា។




**រូបភាពទី ២ ៖ គោលការណ៍រួមស្របតាមគោលការណ៍គោលនយោបាយ**

ផ្អែកលើគោលការណ៍រួមទាំងទិដ្ឋភាពនៃការជ្រើសរើសនិងធ្វើវិកានីយកម្ម និង ទិដ្ឋភាពគោល-នយោបាយដូចបានរៀបរាប់ខាងលើគ្រប់តួអង្គពាក់ព័ន្ធទាំងអស់គួរឈរលើមូលដ្ឋានចាប់ផ្តើមនៃការឈានទៅរកការធ្វើបរិវត្តកម្មឌីជីថលសម្រាប់សេដ្ឋកិច្ច និង សង្គមឌីជីថលនៅកម្ពុជាដោយផ្តោតទៅលើស្នូលនៃឌីជីថលដែលរួមមានទិន្នន័យ និង ថ្នាលឌីជីថល ដើម្បីបង្កើតបានជាសេវាឌីជីថលសម្បូរបែបទៅតាមតម្រូវការប្រកប-ដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, គ្រប់ពេលវេលា និង គ្រប់ទីកន្លែង។

**ទិន្នន័យ៖** គឺជាធាតុផ្សំមួយដ៏ចាំបាច់បំផុតមិនអាចខ្វះបាន សម្រាប់កម្មវិធីបច្ចេកវិទ្យាព័ត៌មានក្នុងការដំណើរការ និងផលិតចេញនូវលទ្ធផលជាច្រើនតាមតម្រូវការ និងគោលបំណងរបស់អ្នកប្រើប្រាស់។ ការកសាងចង្កោមទិន្នន័យគោលមួយចំនួនដូចជា ទិន្នន័យប្រជាសាស្ត្រ, ទិន្នន័យអាជីវកម្ម, ទិន្នន័យពន្ធដារ,

ឯកសារចម្លងពីសាធារណៈ | https://t.me/oa_channel

ទិន្នន័យយានយន្ត និង ទិន្នន័យអចនទ្រព្យ ជាដើមដែលត្រូវគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពជាប្រចាំដោយស្ថាប័នមានសមត្ថកិច្ច ដើម្បីធានាបាននូវសុចរិតភាព និងសង្គតិភាពនៃទិន្នន័យ នៅពេលធ្វើការចែករំលែកជាមួយនឹងស្ថាប័នជំនាញពាក់ព័ន្ធតាមថ្នាលឌីជីថល និងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការធ្វើអភិបាលកិច្ចផ្អែកលើទិន្នន័យ។ ការផ្លាស់ប្តូរទិន្នន័យនៅលើថ្នាលផ្លាស់ប្តូរទិន្នន័យដែលអាចអន្តរប្រតិបត្តិការ និងធ្វើសន្ទានកម្មហើយធានាបាននូវសុវត្ថិភាពទិន្នន័យ និងសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទាំងមូលគឺជាកត្តាចាំបាច់។

**ថ្នាលឌីជីថល៖** ជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលកសាងឡើងដោយមានស្វ័យប្រវត្តិកម្មខ្ពស់ សម្រួលដល់ការអនុវត្តការងារប្រចាំថ្ងៃ។ ក្នុងន័យនេះ, ថ្នាលឌីជីថលដែលជាមូលដ្ឋានត្រូវធ្វើអន្តរប្រតិបត្តិការជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននានា ទាំងរបស់វិស័យសាធារណៈ និងវិស័យឯកជនដើម្បីបំពេញមុខងារឱ្យគ្នាទៅវិញទៅមក និងផ្តល់ជាផតថលសម្រាប់ផ្តល់អន្តរសកម្មជាមួយនឹងធុរជន និង ប្រជាពលរដ្ឋក្នុងការផ្តល់ និងការទទួលសេវា និង ការប្រើប្រាស់ទិន្នន័យ។

**សេវាឌីជីថល៖** គឺជាឌីជីថលផតថល (Portal) ដែលប្រើប្រាស់ដោយប្រជាពលរដ្ឋ, ធុរជន និង បុគ្គលិក/មន្ត្រីរាជរដ្ឋាភិបាលទៅតាមមុខងារ និង គោលបំណងរបស់ឌីជីថលផតថលនីមួយៗ។ សេវាឌីជីថលត្រូវពឹងផ្អែកលើថ្នាលឌីជីថល និង ទិន្នន័យគោលពីប្រភពផ្សេងៗដើម្បីអាចបម្រើមុខងាររបស់ខ្លួនឲ្យកាន់តែមានភាពស្វ័យប្រព្រឹត្តិកម្មខ្ពស់។ ក្នុងន័យនេះ, សេវាឌីជីថលគួរធ្វើអន្តរសកម្មជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់វិស័យឯកជនទៅតាមមុខងាររៀងៗខ្លួន។

ជារួម, ទិន្នន័យ និងថ្នាលឌីជីថលជាស្នូលនៃការធ្វើបរិវត្តកម្មឌីជីថលក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា និងជាមូលដ្ឋាននៃការបង្កើតសេវាឌីជីថលតាមរយៈការប្រើប្រាស់ផតថល។




**រូបភាពទី៣៖ ទំនាក់ទំនងរវាងទិន្នន័យ ថ្នាលឌីជីថល និងសេវាឌីជីថល**

បើពិនិត្យមើល រូបភាពទី ៤ ខាងក្រោម គឺជាឧទាហរណ៍ជាក់ស្តែងនៃការឆ្លើយតបទៅនឹងគោលការណ៍រួមគោលនយោបាយដែលបានបង្ហាញនូវការផ្លាស់ប្តូរទិន្នន័យរវាងទិន្នន័យគោលសំខាន់ៗ របស់ក្រសួង-ស្ថាប័ន មានសមត្ថកិច្ចដូចជាទិន្នន័យអត្តសញ្ញាណកម្មរបស់ក្រសួងមហាផ្ទៃ, ទិន្នន័យចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម, ទិន្នន័យចុះបញ្ជីពន្ធដាររបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទិន្នន័យជូនដំណឹងស្តីពីការបើកសហគ្រាសរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង ទិន្នន័យចុះបញ្ជីសហគ្រាសធុនតូច និងមធ្យមរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ជាដើម ដែលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យគោលទាំងនោះបង្កើតដាច់ដោយឡែកពីគ្នា ប៉ុន្តែមានអន្តរ-ប្រតិបត្តិការ និង សន្ទានកម្មជាប្រព័ន្ធអេកូឡូស៊ីតែមួយដែលប្រជាពលរដ្ឋផ្តល់ទិន្នន័យតែមួយលើក ទិន្នន័យនឹងត្រូវចែករំលែកទៅគ្រប់កន្លែងនៅលើថ្នាលតែមួយដែលអាចបំពេញតម្រូវការរបស់ក្រសួង-ស្ថាប័ន និង បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពខ្ពស់។ បន្ថែមលើនេះ, វិស័យឯកជនក៏អាចផ្លាស់ប្តូរទិន្នន័យនៅលើថ្នាលផ្លាស់ប្តូរទិន្នន័យដោយទំនុកចិត្តខ្ពស់ ដោយសាររាល់ប្រតិបត្តិការនៃការផ្លាស់ប្តូរទិន្នន័យត្រូវធ្វើឃថាភូតកម្ម និង ចុះហត្ថលេខាឌីជីថល(Digital Signature) ក្នុងហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ (Public Key Infrastructure) ដើម្បីធានាបាននូវសុវត្ថិភាព និង សុចរិតភាពទិន្នន័យ ផងដែរ។ ដើម្បីជំរុញ និងពន្លឿនការធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា, រាជរដ្ឋាភិបាលត្រូវបោះជំហានឈានមុខគេក្នុងការប្រើប្រាស់ឌីជីថលដើម្បីបម្រើដល់កិច្ចការស្នូល និង គាំទ្រដល់ការងារកែទម្រង់ពាក់ព័ន្ធ និងជំរុញល្បឿននៃការចាប់យកវិស័យឌីជីថលពីធុរជន និងប្រជាពលរដ្ឋ ខណៈដែលល្បឿននៃការធ្វើបរិវត្តកម្មឌីជីថលប្រព័ន្ធសាធារណៈនៅយឺតនៅឡើយធៀបនឹងកម្រិតមធ្យម នៅក្នុងអនុតំបន់ តំបន់ និង សកល។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលត្រូវផ្តើមចេញពីការរៀបចំ និង ធ្វើទំនើបកម្មទិន្នន័យ, កសាង និងអភិវឌ្ឍថ្នាលឌីជីថល និងការបង្កើនការផ្តល់សេវាសាធារណៈតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យបានកាន់តែច្រើន។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel




រូបភាពទី៤៖ ប្រព័ន្ធអេកូឡូស៊ីនៃការផ្លាស់ប្តូរទិន្នន័យ

### ២.២.២. គោលការណ៍ជាក់លាក់

បន្ថែមលើគោលការណ៍រួមដូចបានកំណត់ខាងលើ, គ្រប់សំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ត្រូវគោរពគោលការណ៍ជាក់លាក់ក្នុងកម្រិតបច្ចេកទេសចំនួន ៨ (ប្រាំបី) បន្ថែមទៀតដូចខាងក្រោម ៖

១). **មុខងារ** (Features)៖ ការជ្រើសរើសមុខងារគឺជាកិច្ចការចាំបាច់ក្នុងការកំណត់ពីភាពជាក់លាក់និងច្បាស់លាស់នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ក្រសួង-ស្ថាប័នត្រូវជ្រើសរើសមុខងារដែលឆ្លើយតបនឹងតម្រូវការ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា និងជាមុខងារដែលគាំទ្រដល់ការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថល និងការលើកកម្ពស់ការផ្តល់សេវាសាធារណៈតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ មុនសម្រេចជ្រើសរើសមុខងារណាមួយ, ក្រសួង-ស្ថាប័នត្រូវប្រាកដថា "មុខងារដែលបានជ្រើសរើសពិតជាបំពេញតម្រូវការបច្ចុប្បន្នរបស់ក្រសួង-ស្ថាប័ន និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា, ហើយត្រូវសួរសំនួរថា "តើមុខងារណាខ្លះដែលមានអាទិភាពខ្ពស់ក្នុងការរៀបចំឬអភិវឌ្ឍផ្អែកទៅតាមលទ្ធភាពធនធាន(ថវិកា, ធនធានមនុស្ស, ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រដល់ប្រព័ន្ធ) និងមុខងារណាខ្លះដែលត្រូវអភិវឌ្ឍក្នុងដំណាក់កាលបន្តបន្ទាប់?"។

២). **ភាពងាយស្រួលក្នុងការប្រើប្រាស់** (User-friendliness)៖ គម្រោងត្រូវអនុវត្តតាមគោលការណ៍ភាពងាយស្រួលក្នុងការប្រើប្រាស់ដែលជាគោលការណ៍សំខាន់ ក្នុងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានពីគ្រប់តួអង្គពាក់ព័ន្ធទាំងរដ្ឋ, ពលរដ្ឋ និង ធុរជន សំដៅជំរុញការធ្វើបរិវត្តកម្មឌីជីថលពេញលេញនៅកម្ពុជា។ ក្រសួង-ស្ថាប័នត្រូវគិតគូរទៅលើការរៀបចំ ឬ អភិវឌ្ឍន៍គេហទំព័រ ឬផលិតផលដែលជានាបាននូវសង្គតិភាពនៃរូបរាងការរចនាផ្ទាំងកម្មវិធីអ្នកប្រើប្រាស់ (User Interface) ឬ បទពិសោធន៍របស់អ្នកប្រើប្រាស់ (User Experience) តាមរយៈការអនុវត្តតាមឯកសារណែនាំស្តង់ដាគំរូ (Standard Template) លើពិធីសារ, លក្ខណៈបច្ចេកទេស, រូបរាងរចនាផលិតផល (UI/UX) ជាដើម ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

៣). **សន្តិសុខឌីជីថល** (Security)៖ ក្រសួង-ស្ថាប័នត្រូវគិតគូរទៅលើការគ្រប់គ្រង និងការពារសន្តិសុខឌីជីថលដោយត្រូវគិតទាំងស្តង់ដាសន្តិសុខព័ត៌មាន និងសុវត្ថិភាពទិន្នន័យនៃគម្រោងតាមរយៈការកំណត់នីតិវិធីសុវត្ថិភាព និងការបំពាក់សម្ភារបរិក្ខារបច្ចេកទេសសម្រាប់តាមដាន ត្រួតពិនិត្យ និងទប់ស្កាត់ការវាយប្រហារនានា ស្របតាមស្តង់ដាសន្តិសុខឌីជីថល និងត្រូវការពារទិន្នន័យឯកជនរបស់បុគ្គលក្នុងគោលដៅការពារសិទ្ធិ សេរីភាព សេចក្តីថ្លៃថ្នូរ និងគុណតម្លៃដើម្បីបង្កើនភាពជឿជាក់ និងទំនុកចិត្តរបស់ប្រជាពលរដ្ឋ និង ធុរជនលើការប្រើប្រាស់សេវាឌីជីថលដែលក្រសួង-ស្ថាប័នផ្តល់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ក្រសួង-ស្ថាប័ន ត្រូវតែគោរពតាមស្តង់ដាសន្តិសុខឌីជីថលរបស់រដ្ឋាភិបាលដែលមានជាធរមានដែលកំណត់អំពីបច្ចេកសព្ទ យន្តការក្របខណ្ឌបច្ចេកទេសប្រតិបត្តិការ ប្រព័ន្ធគ្រប់គ្រងសន្តិសុខឌីជីថល និងក្រមអនុវត្តសម្រាប់ការត្រួតពិនិត្យសន្តិសុខឌីជីថលក្នុងគោលដៅធានាសន្តិសុខ និង សុវត្ថិភាពនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

៤). **ភាពបត់បែន (Flexibility)៖** គម្រោងត្រូវបង្ហាញនូវភាពបត់បែនស្របការវិវត្តនៃបច្ចេកវិទ្យា, មានភាពទន់ភ្លន់ក្នុងការកែប្រែប្រព័ន្ធឱ្យស្របតាមការផ្លាស់ប្តូរបទដ្ឋានគតិយុត្ត និង មិនមានភាពស្មុគស្មាញក្នុងការធ្វើទំនើបកម្មលើប្រព័ន្ធ, សេវា ឬហេដ្ឋារចនាសម្ព័ន្ធឌីជីថល ទៅកាន់ជំនាន់ថ្មី។ ក្រសួង-ស្ថាប័នត្រូវជ្រើសរើសបច្ចេកវិទ្យាដែលអាចបត់បែន និងសម្របបានតាមការវិវត្ត និងការកើនឡើងនៃតម្រូវការ។ ដើម្បីវាយតម្លៃភាពបត់បែននៃបច្ចេកវិទ្យាព័ត៌មាន, ក្រសួង-ស្ថាប័នត្រូវប្រាកដថា នៅពេលមានការកែប្រែ ឬ ផ្លាស់ប្តូរមុខងារណាមួយនៅពេលអនាគត ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលត្រូវបានជ្រើសរើសអាចបត់បែនបាន ហើយដំណើរការនៃប្រព័ន្ធមិនចាំបាច់ត្រូវសរសេរកូដ ឬ រៀបចំឡើងវិញ ទាំងស្រុង។

៥). **នវានុវត្តន៍ (Innovation)៖** ក្រសួង-ស្ថាប័នអាចបង្កើន, ពង្រីក និងនវានុវត្តន៍ការប្រើប្រាស់ប្រព័ន្ធ និងកម្មវិធីបច្ចេកវិទ្យាព័ត៌មានតាមរយៈការរៀបចំ, អភិវឌ្ឍ និងនវានុវត្តន៍ប្រព័ន្ធគាំទ្រដល់មុខងារស្នូលរបស់អង្គភាព, នវានុវត្តន៍ប្រព័ន្ធគ្រប់គ្រងកិច្ចការបុគ្គលិក រដ្ឋបាល និងបណ្តុះបណ្តាល និង នវានុវត្តន៍ប្រព័ន្ធគ្រប់គ្រងការទំនាក់ទំនង និង កិច្ចសហប្រតិបត្តិការរួម ដែលគម្រោងនវានុវត្តន៍ទាំងនោះអាចសម្របខ្លួនបានលឿនទៅតាមការវិវត្តនៃនិន្នាការបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថលសាកលដែលមានការរីកចម្រើន និងអភិវឌ្ឍជាលំដាប់។ បន្ថែមលើនេះ, ការចាប់យកនិន្នាការបច្ចេកវិទ្យាព័ត៌មានថ្មីៗ គាំទ្រដល់ការធ្វើឌីជីថលូបនីយកម្មដែលរួមមានការប្រើប្រាស់បច្ចេកវិទ្យាទិន្នន័យធំ (Big Data), វិទ្យាសាស្ត្រទិន្នន័យ (Data Science), បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (Artificial Intelligent-AI ឬ Machine Learning-ML), បច្ចេកវិទ្យាក្លោដ (Cloud Technology), អ៊ីនធឺណិតនៃវត្ថុ (IoT), ប្លុកឆេន (Blockchain) ជាដើម គាំទ្រដល់ការងារស្ថិតិ, វិភាគ និងព្យាករណ៍, ការធ្វើស្វ័យប្រវត្តិកម្មការងារ ឬ ថ្នាលបច្ចេកវិទ្យាព័ត៌មាននានា និង បច្ចេកវិទ្យាថ្មីៗដែលមានប្រយោជន៍គាំទ្រដល់ការងារបែបឌីជីថល។

៦). **ចំណាយក្នុងការតម្លើង (Setup Costs)៖** ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានរៀបចំ និង កសាងឡើងជាច្រើនទៅតាមតម្រូវការរបស់ក្រសួង-ស្ថាប័ននីមួយៗ ។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានធំៗមួយចំនួនត្រូវបានប្រើប្រាស់ផលិតផលដែលមានស្រាប់របស់ក្រុមហ៊ុនធំៗ នៅក្នុងទីផ្សារអន្តរជាតិ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយចំនួនទៀតត្រូវបានរៀបចំ និង អភិវឌ្ឍដោយប្រើប្រាស់ធនធានមនុស្សរបស់ក្រសួង-ស្ថាប័នផ្ទាល់។ ប្រព័ន្ធទាំងពីរមានបញ្ហាប្រឈមរៀងៗខ្លួនដោយប្រព័ន្ធដែលប្រើប្រាស់ផលិតផលស្រាប់ ផ្តល់ភាពស្មុគស្មាញក្នុងការធ្វើទំនើបកម្មបច្ចេកវិទ្យាព័ត៌មានទៅកាន់ជំនាន់ថ្មី, ភាពខ្វះចន្លោះលើព័ត៌មានពាក់ព័ន្ធនឹងប្រភេទអាជ្ញាបណ្ណនៃបច្ចេកវិទ្យាព័ត៌មាននីមួយៗ និងការប្រើប្រាស់មុខងារមិនទាន់អស់សមត្ថភាពដែលប្រព័ន្ធមាន។ ចំពោះការប្រើប្រាស់ប្រព័ន្ធដែលផលិតដោយខ្លួនឯង, ក្រសួង-ស្ថាប័នមិនទាន់មានឯកសារគោលនៃប្លង់និម្មាបនកម្មនៃការអភិវឌ្ឍប្រព័ន្ធដែលត្រូវរក្សាទុក និងតម្កល់ជាទ្រព្យឯកសារសម្រាប់ការបន្តអភិវឌ្ឍនៅគ្រប់ជំនាន់, ខ្វះយន្តការក្នុងការគ្រប់គ្រងកូដដើម (Source Code) នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗដែលបានផលិតឡើងដោយ

ធនធានមនុស្សរបស់អង្គភាពនាំឱ្យ "បុគ្គលិកលាឈប់ពីការងារ, ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន មានការលំបាកក្នុងការបន្តការអភិវឌ្ឍ, ខ្វះការគិតគូរជាក្របខណ្ឌរួម និងរៀបចំឡើងនូវប្រព័ន្ធតូចៗ ដាច់ដោយឡែកពីគ្នា និងអាចមានភាពស្ទួនគ្នាពីអង្គភាពមួយទៅអង្គភាពមួយ។ ដូច្នេះ ទាំងការទិញផលិតផលស្រាប់មកប្រើ និងការផលិតដោយខ្លួនឯងសុទ្ធតែត្រូវការចំណាយលើការរៀបចំ និងការតម្លើងខ្ពស់។ ក្នុងន័យនេះ, គម្រោងដែលស្នើឡើងត្រូវបរិយាយលម្អិតអំពីតម្លៃនៃការរៀបចំ និងការតម្លើងប្រព័ន្ធបច្ចេកវិទ្យាឱ្យបានគត់មត់ និង មានផែនការតម្លើងច្បាស់លាស់ដើម្បីជៀសវាងចំណាយអស់ច្រើនក្នុងការតម្លើង ហើយត្រូវបន្តចំណាយខ្ពស់ទៅលើការថែទាំ រួមទាំងការបង់ថ្លៃអាជ្ញាបណ្ណ និងចំណាយផ្សេងៗទៀត។

៧). **ចំណាយសម្រាប់អាជ្ញាបណ្ណ (License Costs)៖** ការជ្រើសរើសបច្ចេកវិទ្យាព័ត៌មានយកមកប្រើប្រាស់គឺជាកត្តាសំខាន់មួយសម្រាប់គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលក្រសួង-ស្ថាប័នត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះការទទួលឬការទិញអាជ្ញាបណ្ណបច្ចេកវិទ្យា ។ ក្រសួង-ស្ថាប័នត្រូវសិក្សា ឬស្វែងយល់ឱ្យបានច្បាស់លាស់ថាតើត្រូវបង់អ្វីខ្លះជាប្រចាំ ឬ ជារៀងរាល់ឆ្នាំទៅលើអាជ្ញាបណ្ណដើម្បីអនុញ្ញាតឱ្យប្រព័ន្ធបច្ចេកវិទ្យាដំណើរការបាន និងមាននិរន្តភាព។ ក្រសួង-ស្ថាប័នត្រូវប្រាកដពីអ្វីដែលខ្លួននឹងត្រូវចំណាយ ហើយត្រូវប្រាកដថាតើមុខងារណាខ្លះដែលប្រព័ន្ធអាចប្រើប្រាស់បាន។ ជាក់ស្តែង, អ្នកផ្តល់ផលិតផល/សេវាកម្មឌីជីថលតែងរួមបញ្ចូលមុខងារមួយចំនួន ដែលក្រសួង-ស្ថាប័នមិនមានតម្រូវការនៅក្នុងដំណាក់កាលអភិវឌ្ឍ ឬ ប្រើប្រាស់ប្រព័ន្ធដំបូង ប៉ុន្តែក្រសួង-ស្ថាប័នត្រូវបង់អាជ្ញាបណ្ណសម្រាប់មុខងារដែលមិនបាន ឬ មិនទាន់ប្រើប្រាស់ក្នុងតម្លៃថ្លៃ។ ក្រៅពីការសិក្សាលើការចំណាយចំពោះអាជ្ញាបណ្ណ ក្រសួង-ស្ថាប័នក៏ត្រូវបានលើកទឹកចិត្តឲ្យសិក្សាចំពោះប្រព័ន្ធបើកចំហ (Open-Source) ដែលមានតម្លៃ និង ផ្តល់អត្ថប្រយោជន៍ប្រហាក់ប្រហែលនឹងប្រព័ន្ធដែលត្រូវការអាជ្ញាបណ្ណផងដែរ។ ក្នុងន័យនេះ, ក្រសួង-ស្ថាប័នត្រូវគិតគូរឱ្យបានម៉ត់ចត់មុននឹងសម្រេចចិត្តទិញអាជ្ញាបណ្ណ ជៀសវាងការទិញអាជ្ញាបណ្ណដែលមានតម្លៃថ្លៃ ប៉ុន្តែផ្តល់ប្រសិទ្ធភាពតិចតួចដល់ការផ្តល់សេវាសាធារណៈ ហើយរាជរដ្ឋាភិបាលត្រូវបន្ថែមបន្ទុករដ្ឋបាល (Operation Cost) ដើម្បីរក្សាដំណើរការនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលប្រើប្រាស់អាជ្ញាបណ្ណទាំងនោះ។

៨). **ចំណាយលើការថែទាំ (Maintenance Costs)៖** ក្រសួង-ស្ថាប័នបានរៀបចំ កសាង និងកំពុងដំណើរការនូវធនធានរួមមានឧបករណ៍, ហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្សជាដើមដើម្បីគាំទ្រដល់ដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗគ្នា ដែលការណ៍នេះ បានបង្កើនបន្ទុកចំណាយវិនិយោគច្រើនទាំងពេលតម្លើងដំបូង និងពេលផ្លាស់ប្តូរ ឬ បំពាក់បន្ថែមឧបករណ៍ថ្មី, បង្កើនបន្ទុកចំណាយចរន្តលើការប្រើប្រាស់សេវាថែទាំគាំទ្រប្រចាំឆ្នាំ, បង្កើនបន្ទុកចំណាយលើបុគ្គលិក ដែលស្ថិតក្នុងក្របខណ្ឌការងារបច្ចេកទេសដូចគ្នា រួមមានផ្នែកគ្រប់គ្រងមជ្ឈមណ្ឌលទិន្នន័យ, ផ្នែកអគ្គិសនី, ផ្នែកសន្តិសុខបច្ចេកវិទ្យាព័ត៌មាន, ផ្នែកម៉ាស៊ីនមេ, ផ្នែកបណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានជាដើម និងបង្កើនបន្ទុកចំណាយចរន្តលើការប្រើប្រាស់ថាមពលអគ្គិសនីច្រើនកន្លែង។ បន្ថែមលើនេះ, បច្ចេកវិទ្យាមួយចំនួនតម្រូវ

ឯកសារមាន្ត្រីសាធារណៈ | https://t.me/oa_channel

ឱ្យក្រសួង-ស្ថាប័នត្រូវបំពាក់ឧបករណ៍ស្ទួនជូនអ្នកប្រើប្រាស់តែមួយ ដោយសារហេតុផលនៃការពង្រឹងសន្តិសុខទិន្នន័យ និងសន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននីមួយៗបានធ្វើឱ្យមន្ត្រី ឬ បុគ្គលិកនៃអង្គភាពមួយចំនួនត្រូវបានបំពាក់ម៉ាស៊ីនកុំព្យូទ័រលើសពី ១ គ្រឿងនៅលើតុធ្វើការងាររបស់ខ្លួនរួមទាំងការតភ្ជាប់បណ្តាញបច្ចេកវិទ្យាព័ត៌មានលើសពីមួយ (១) ផងដែរ។ ក្នុងន័យនេះបុគ្គលិកឬមន្ត្រីម្នាក់អាចមានម៉ាស៊ីនកុំព្យូទ័រ និង បណ្តាញតភ្ជាប់ពីរ-បី (២-៣) ផ្សេងគ្នានៅលើតុធ្វើការតែមួយដោយសារម៉ាស៊ីន និង បណ្តាញ តភ្ជាប់ទាំងនោះត្រូវប្រើប្រាស់ដាច់ដោយឡែកពីគ្នា ដែលការណ៍នេះបានបង្កឱ្យមានការខាតបង់ និង ខ្ជះខ្ជាយធនធានថវិកាយ៉ាងធ្ងន់ធ្ងរសម្រាប់ក្រសួង-ស្ថាប័នក្នុងការចំណាយទៅលើឧបករណ៍ និង ការភ្ជាប់បណ្តាញបច្ចេកវិទ្យាព័ត៌មាន។ ដើម្បីបង្កើនប្រសិទ្ធភាពចំណាយ និងកាត់បន្ថយចំណាយលើការថែទាំដែលមិនចាំបាច់, ក្រសួង-ស្ថាប័នត្រូវលើកយកករណី ឬ បញ្ហាប្រឈមជាក់ស្តែងមកសិក្សា, វិភាគ និង កំណត់នូវវិធានការសម្រាប់តម្រង់ទិសឈានទៅរកការប្រើប្រាស់ឧបករណ៍ និង បណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មានរួមតែមួយសម្រាប់ប្រព័ន្ធផ្សេងៗគ្នាដោយផ្តោតជាសំខាន់ទៅលើកត្តាសន្តិសុខបច្ចេកវិទ្យាព័ត៌មាន និង ការប្រើប្រាស់បណ្តាញរួមស្របតាមតម្រូវការជាក់ស្តែង។




**រូបភាពទី ៥ ៖ គោលការណ៍ជាក់លាក់នៃការវាយតម្លៃសំណើគម្រោង**

## ២.៣. អភិក្រមនៃការវាយតម្លៃ

ការវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ត្រូវឈរលើអភិក្រមនៃការពិនិត្យ និងផ្តល់យោបល់ទាំងទិដ្ឋភាពបច្ចេកទេស និងទិដ្ឋភាពហិរញ្ញវត្ថុក្នុងទម្រង់ជាគុណវិស័យ (Qualitative) និង បរិមាណវិស័យ (Quantitative) ដោយពិនិត្យទៅលើគោលការណ៍រួមទាំង ១១ ចំណុច និង គោលការណ៍ជាក់លាក់ទាំង ៨ ចំណុចដូចបានរៀបរាប់ខាងលើ ដូចមានបង្ហាញក្នុងរូបទី ៦ ជារួមដូចខាងក្រោម។ បន្ថែមលើនេះ, ការវាយតម្លៃ ត្រូវអនុវត្តតាមវិធីសាស្ត្រ ដែលមានលក្ខណៈសត្យានុម័ត ដើម្បីបញ្ចៀសឱ្យបានភាពលម្អៀង តាមរយៈការដាក់ពិន្ទុ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលមានបង្ហាញលម្អិត នៅក្នុងឧបសម្ព័ន្ធទី ១ នៃក្របខណ្ឌវាយតម្លៃសំណើគម្រោងនេះ ។




**រូបភាពទី ៦ ៖ក្របខណ្ឌរួមនៃការវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍**

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

## ៣. យន្តការនៃការវាយតម្លៃ

### ៣.១. វិសាលភាពនៃការវាយតម្លៃ

គ្រប់គម្រោងវិនិយោគសាធារណៈ ត្រូវអនុលោមតាមអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ ដែលមានការបែងចែកវដ្តនៃគម្រោងវិនិយោគសាធារណៈ ជា ៨ ដំណាក់កាល (មាត្រា ៨) ដូចខាងក្រោម ៖

**ទី១. ការធ្វើអត្តសញ្ញាណកម្ម និងការរៀបចំសំណើគម្រោងបឋម ៖** ក្រសួង-ស្ថាប័នជំនាញត្រូវកំណត់អត្តសញ្ញាណគម្រោង, រៀបចំសំណើគម្រោងបឋម ឬ ឯកសារទស្សនាទានគម្រោង ដោយអនុលោមតាមគោលនយោបាយជាតិ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលនយោបាយតាមវិស័យ, ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និង ក្របខណ្ឌថវិការយៈពេលមធ្យម ដើម្បីធ្វើអាទិភាវូបនីយកម្មសំណើគម្រោងវិនិយោគ សម្រាប់ដាក់បញ្ចូល ទៅក្នុងផែនការវិនិយោគសាធារណៈ។

**ទី២. ការសិក្សាសមិទ្ធិលទ្ធភាព និងការវាយតម្លៃសំណើគម្រោង ៖** ក្រសួង-ស្ថាប័នជំនាញត្រូវសិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃសំណើគម្រោងលើទិដ្ឋភាពពាក់ព័ន្ធ រួមមាន៖ បច្ចេកទេស, តម្លៃ, ហានិភ័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ច្បាប់, ផលប៉ះពាល់បរិស្ថាន និងសង្គម ព្រមទាំងយន្តការ និងសមត្ថភាពស្ថាប័ន សម្រាប់គ្រប់គ្រង និងតាមដានការអនុវត្តគម្រោង ដោយត្រូវគោរពតាមគោលការណ៍ស្តីពីការសិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃសំណើគម្រោង ដែលមានជាធរមាន ។

**ទី៣. ការពិនិត្យ និង វាយតម្លៃលើសំណើគម្រោង ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវពិនិត្យផ្ទៀងផ្ទាត់ឡើងវិញលើការវាយតម្លៃសំណើគម្រោងរបស់ក្រសួង-ស្ថាប័នជំនាញ។ នៅក្នុងក្របខណ្ឌវាយតម្លៃសំណើគម្រោង ICT, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវសម្របសម្រួលជាមួយក្រុមការងារចម្រុះក្នុងការពិនិត្យ និងផ្តល់យោបល់ទាំងទិដ្ឋភាពបច្ចេកទេស និងហិរញ្ញវត្ថុដូចមានបង្ហាញក្នុងរូបភាពទី៧ ខាងក្រោម។

**ទី៤. ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាព ដែលបានឆ្លងកាត់ដំណាក់កាលទី ៣ ដើម្បីកំណត់ប្រភពហិរញ្ញប្បទាន និងធ្វើថវិកានីយកម្ម ក្នុងគោលដៅធានាប្រសិទ្ធភាពសេដ្ឋកិច្ច, សមធម៌សង្គម និងលទ្ធភាពនៃថវិកា ក្នុងដំណាក់កាលវិនិយោគ, ប្រតិបត្តិការ និងថែទាំ ។ មានតែគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អនុលោមតាមលក្ខណៈវិនិច្ឆ័យ និងវិធានជាធរមានប៉ុណ្ណោះ ដែលនឹងត្រូវបានជ្រើសរើសចេញពីបញ្ជីគម្រោងអាទិភាព សម្រាប់ការធ្វើថវិកានីយកម្ម ។ តារាងសង្ខេបអំពីបញ្ជីគម្រោងវិនិយោគសាធារណៈ ដែលត្រូវបានជ្រើសរើសសម្រាប់ការធ្វើថវិកានីយកម្ម ត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ។

**ទី៥. ការគ្រប់គ្រង និងការអនុវត្តគម្រោង ៖** ដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នជាម្ចាស់សំណើគម្រោង ត្រូវចាប់ផ្តើមអនុវត្តកិច្ចលទ្ធកម្ម រាប់ទាំងការរៀបចំផែនការ, ការអនុវត្តនីតិវិធីលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា ។ ចំពោះករណីគម្រោងវិនិយោគដែលមានទំហំមធ្យម ឬ ធំ ត្រូវរៀបចំក្នុងក្របខណ្ឌនៃកញ្ចប់ថវិកាពហុឆ្នាំ។

**ទី៦. ការកែសម្រួលគម្រោង ៖** ក្រសួង-ស្ថាប័នជំនាញ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវតាមដានការអនុវត្តគម្រោង ដោយត្រូវផ្ទៀងផ្ទាត់វឌ្ឍនភាពនៃការអនុវត្តគម្រោង ទៅនឹងផែនការអនុវត្តគម្រោង និងកែសម្រួលគម្រោងតាមការចាំបាច់។

**ទី៧. ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមគម្រោង ៖** ក្រសួង-ស្ថាប័នជំនាញត្រូវត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ឈានទៅធ្វើសេចក្តីសម្រេចលើការប្រគល់-ទទួលការដាក់ឱ្យប្រើប្រាស់ និងការចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋ តាមនីតិវិធីជាធរមាន និង

**ទី៨. ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង ៖** ក្រសួង-ស្ថាប័នជំនាញត្រូវចាត់ចែងរៀបចំការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង ដោយត្រូវរៀបចំចងក្រងជារបាយការណ៍ស្តីពីលទ្ធផលសម្រេចបាន ទាំងលទ្ធផលសម្រេចបានក្នុងរយៈពេលអនុវត្តគម្រោង ទាំងលទ្ធផលចុងក្រោយ ព្រមទាំងបញ្ហាប្រឈមនៃការអនុវត្តគម្រោង សម្រាប់ជាបទពិសោធន៍ក្នុងការរៀបចំ និង អនុវត្តគម្រោងវិនិយោគសាធារណៈក្រោយៗទៀត ។




**រូបភាពទី ៧ ៖ ដំណាក់កាលនៃការពិនិត្យ និងផ្តល់យោបល់បច្ចេកទេស**
**លើសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍**

ដូចមានបង្ហាញក្នុងរូបភាពទី ៧ ខាងលើ (ដំណាក់កាលទី ៣), ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ត្រូវបានរៀបចំឡើង ដើម្បីចូលរួមពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើ **គ្រប់សំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ ដែលមានចរិតលក្ខណៈជាគម្រោងរដ្ឋាភិបាលឌីជី-ថល និង/ឬ គម្រោងសេដ្ឋកិច្ច, ធុរកិច្ច និង សង្គមឌីជីថល ពីគ្រប់ប្រភពហិរញ្ញប្បទាន និង គ្រប់កម្រិតរដ្ឋបាល**

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

សំដៅធានាឱ្យបាននូវសុខដុមនីយកម្មការវិនិយោគឱ្យចំគោលដៅ និងការចែករំលែកការប្រើប្រាស់ធនធានបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ឱ្យអស់សក្តានុពល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់ ។

### ៣.២. យន្តការសម្របសម្រួល

យន្តការសម្របសម្រួលសំណើគម្រោង ត្រូវអនុវត្តតាមយន្តការដែលមានស្រាប់ជាធរមាន ស្របតាមនីតិវិធីដែលបានអនុវត្តកន្លងមក ។ យ៉ាងណាមិញ, ដើម្បីឱ្យការពិនិត្យ និងផ្តល់យោបល់កាន់តែមានភាព-ច្បាស់លាស់ និង ស្របតាមគោលការណ៍ និង ក្របខណ្ឌនេះ, ការទទួលសំណើគម្រោងរួមទាំងសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ដែលជាគម្រោងថ្មីតូច-មធ្យម, គម្រោងដែលធ្លាប់ទទួលបានការសម្រេចរួចហើយនិងត្រូវអនុវត្តបន្ត និង មានលក្ខណៈជាប្រចាំ នឹងត្រូវធ្វើដោយត្រង់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានក្រុមការងារបច្ចេកទេសផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកពិនិត្យ និងផ្តល់យោបល់។ ចំពោះសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ដែលជាគម្រោងវិនិយោគថ្មី និងមានទំហំធំ និង/ឬមានលក្ខណៈស្មុគស្មាញ ត្រូវពិនិត្យ និងផ្តល់យោបល់ដោយក្រុមការងារចម្រុះដែលមានសមាសភាពពីគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និងអ្នកពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់ ។ សមាសភាពជាក់ស្តែងនៃក្រុមការងារចម្រុះត្រូវតែងតាំងដោយសេចក្តីសម្រេច ។

បន្ទាប់ពីទទួលបានការពិនិត្យនិងផ្តល់យោបល់ពីក្រុមការងារចម្រុះ, គ្រប់សំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ទាំងអស់ត្រូវពិនិត្យ និងសម្រេចចុងក្រោយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាទ្វារបាលនៃការគ្រប់គ្រងគម្រោងវិនិយោគសារធារណៈ និងជាសេនាធិការរបស់រាជរដ្ឋាភិបាលដោយអនុ-លោមតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងយន្តការដែលមានជាធរមាន។




រូបភាពទី ៨ ៖ យន្តការសម្របសម្រួល

## ៣.៣. ការបែងចែកតួនាទី និងភារកិច្ច

ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍នេះ ត្រូវប្រើប្រាស់ដោយ ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាម្ចាស់គម្រោង, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមការងារចម្រុះដែលត្រូវមានតួនាទីនិងភារកិច្ច (បន្ថែមលើតួនាទី និងភារកិច្ច ដែលមានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន) ដូចខាងក្រោម ។

### ៣.៣.១. ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាម្ចាស់គម្រោង ត្រូវមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើអត្តសញ្ញាណកម្ម និងរៀបចំឯកសារទស្សនាទានគម្រោង,
- ធ្វើអាទិភាវូបនីយកម្ម,
- ធ្វើផែនការនីយកម្មការវិនិយោគសាធារណៈ,
- រៀបចំឯកសារសំណើគម្រោង ដោយត្រូវភ្ជាប់ជាមួយនូវរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព និងរបាយការណ៍វាយតម្លៃសំណើគម្រោង,
- គ្រប់គ្រងការអនុវត្តគម្រោង,
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង, របាយការណ៍ក្រោយបញ្ចប់ការអនុវត្តគម្រោង និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀត,
- បំពេញតួនាទី និងភារកិច្ចពាក់ព័ន្ធផ្សេងទៀត ។

### ៣.៣.២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ពិនិត្យ និងវាយតម្លៃលើសំណើគម្រោង ដោយត្រូវពិនិត្យលើតម្លៃ និងហានិភ័យគម្រោង, ផល-ចំណេញផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃគម្រោង, យន្តការគ្រប់គ្រង និងអនុវត្តគម្រោង ព្រមទាំងកំណត់នូវវិធានការចាំបាច់នានា ដើម្បីកែតម្រូវ និងគ្រប់គ្រងហានិភ័យគម្រោង,
- សម្របសម្រួលជាមួយ ក្រុមការងារចម្រុះសម្រាប់សំណើគម្រោងវិនិយោគថ្មី និងមានទំហំធំ និង/ឬ មានលក្ខណៈស្មុគស្មាញ ក្នុងការពិនិត្យ និងផ្តល់យោបល់បច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីប្រើប្រាស់ជាមូលដ្ឋានក្នុងការជ្រើសរើសគម្រោង និងការធ្វើថវិកានីយកម្មប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងតម្លាភាព,
- ជ្រើសរើស និងធ្វើថវិកានីយកម្មសំណើគម្រោង ដោយត្រូវជ្រើសរើសគម្រោងពីបញ្ជីគម្រោងអាទិភាព ដើម្បីធ្វើថវិកានីយកម្ម ក្នុងគោលដៅធានាឱ្យបានភាពឆ្លើយតបទៅនឹងតម្រូវការជា

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

អាទិភាព, ប្រសិទ្ធភាពសេដ្ឋកិច្ច, សមធម៌សង្គម, លទ្ធភាពនៃថវិកា និងភាពរួចរាល់នៃការចាប់ផ្ដើមអនុវត្ត និងភាពដែលអាចអនុវត្តបាន,

- តាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង ដោយពិនិត្យលើការគ្រប់គ្រង និងអនុវត្តគម្រោង និងវាយតម្លៃអនុលោមភាពតាមវិធាន, គោលការណ៍ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ,
- បំពេញមុខងារជាទ្វារបាលនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈទាំងអស់ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន, និង
- បំពេញតួនាទី និងភារកិច្ចពាក់ព័ន្ធផ្សេងទៀត ។

### ៣.៣.៣. ក្រុមការងារចម្រុះ

ក្រុមការងារចម្រុះ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យ និងផ្ដល់យោបល់លើទិដ្ឋភាពបច្ចេកទេស និង ហិរញ្ញវត្ថុលើសំណើគម្រោងវិនិយោគថ្មី មានទំហំធំ និង មានលក្ខណៈស្មុគស្មាញដើម្បីបន្តនីតិវិធីអនុលោម តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន,
- បូកសរុប និងផ្ដល់របាយការណ៍ពិនិត្យ និងផ្ដល់យោបល់លើសំណើគម្រោងជូនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេចចុងក្រោយស្របតាមនីតិវិធីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន,
- បំពេញតួនាទី និងភារកិច្ចពាក់ព័ន្ធផ្សេងទៀតតាមការចាំបាច់ ។

## ៤. ការគ្រប់គ្រង និង តាមដានការវាយតម្លៃ និងការអនុវត្តគម្រោង

ក្នុងគោលដៅធានាប្រសិទ្ធភាពនៃការវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍, ការគ្រប់គ្រង និងតាមដានការអនុវត្តគម្រោង, ការសម្របសម្រួលរវាងគ្រប់ភាគីក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ និងការរាយការណ៍ឱ្យបានទាន់ពេលវេលា ជាពិសេសការប្រមូលនូវទិន្នន័យសំខាន់ៗរបស់គម្រោងដែលបង្កើតបានជាព័ត៌មានសម្រាប់ជួយដល់ការសម្រេចចិត្ត ប្រកបដោយប្រសិទ្ធភាព, **ប្រព័ន្ធគ្រប់គ្រងគម្រោងបច្ចេកវិទ្យាព័ត៌មាន** មួយ នឹងត្រូវរៀបចំឡើង ដែលមានមុខងារមូលដ្ឋានសំខាន់ៗ ដូចខាងក្រោម ៖

- **មុខងារបញ្ចូលព័ត៌មានគម្រោង ៖** ប្រព័ន្ធនឹងកត់ត្រា និងរក្សាទុកទិន្នន័យសំខាន់ៗរបស់គម្រោង ដែលជាមូលដ្ឋានសម្រាប់ពិនិត្យ និងផ្ដល់យោបល់ ទៅតាមក្របខណ្ឌនៃការវាយតម្លៃគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ។ ប្រព័ន្ធនឹងរក្សាទុកនូវឯកសារគាំទ្រគម្រោងផ្សេងៗក្នុងទម្រង់ឌីជីថល ដើម្បីងាយស្រួល ក្នុងការទាញយកមកប្រើប្រាស់ពីក្នុងប្រព័ន្ធ,
- **មុខងារបញ្ជីគម្រោង ៖** ប្រព័ន្ធនឹងបង្ហាញព័ត៌មានសំខាន់ៗមួយចំនួនរបស់គម្រោងនីមួយៗ ដែលបានបញ្ចូលទិន្នន័យរួចរាល់ និងបង្ហាញពីស្ថានភាពរបស់គម្រោង,

- **មុខងារវាយតម្លៃគម្រោង ៖** គម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ នឹងត្រូវបានវាយតម្លៃ និងដាក់ពិន្ទុទៅតាមលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ ហើយប្រព័ន្ធនឹងធ្វើការគណនា និងប្រមូលទិន្នន័យ ដើម្បីរៀបចំចងក្រងជារបាយការណ៍,
- **មុខងារគ្រប់គ្រងធនធានគម្រោង ៖** ប្រព័ន្ធនឹងគ្រប់គ្រងព័ត៌មានអំពីធនធានរបស់គម្រោង ដែលអាចជាអាជ្ញាបណ្ណ, ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ឬធនធានផ្សេងទៀត ដែលបានប្រើ-ប្រាស់ថវិកាគម្រោង ជាដើម,
- **មុខងាររបាយការណ៍ ៖** ប្រព័ន្ធនឹងប្រមូលព័ត៌មានគម្រោងទាំងអស់ ហើយបង្កើតជារបាយ-ការណ៍សង្ខេប ឬព័ត៌មានស្ថិតិផ្សេងៗ ដែលផ្តល់ជាទស្សនាទានរួមទូទៅ ក្នុងការពិនិត្យលើទិដ្ឋភាពនៃការវាយតម្លៃគម្រោង និងទិដ្ឋភាពហិរញ្ញវត្ថុ ។ ព័ត៌មានទាំងនេះ នឹងបម្រើជាធាតុចូលយ៉ាងសំខាន់ ដែលគាំទ្រដល់ការរៀបចំគោលនយោបាយជាយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់វិស័យឌីជីថល និង
- **មុខងារផ្សេងៗ ៖** មុខងារបន្ទាប់បន្សំ សម្រាប់កំណត់សិទ្ធិនៃការប្រើប្រាស់ទិន្នន័យមួយចំនួន ដើម្បីធានាបាននូវអនុលោមភាពនៃប្រព័ន្ធ ។

ប្រព័ន្ធគ្រប់គ្រងគម្រោងបច្ចេកវិទ្យាព័ត៌មាន នឹងត្រូវបង្កើតឡើងជាដំណាក់កាល និងបង្កើនមុខងារ និងសមត្ថភាពតាមតម្រូវការចាំបាច់ជាក់ស្តែង ដោយមុខងារខាងលើ នឹងត្រូវបង្កើតក្នុងដំណាក់កាលដំបូង។

## ៥. ការគ្រប់គ្រងហានិភ័យ

ការវិវត្តយ៉ាងលឿន និងភាពស្មុគស្មាញនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អាចបង្កជាហានិភ័យ និងបញ្ហាប្រឈម ផ្ទាល់ និង ប្រយោល ដល់ការអនុវត្ត **ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍** ឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់។ ការណ៍នេះ ទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធមានភាពបុរេសកម្មខ្ពស់ ក្នុងការកំណត់ និងគ្រប់គ្រងហានិភ័យធំៗ ដែលអាចបង្កឱ្យមានភាពបរាជ័យក្នុងការអនុវត្ត ក្របខណ្ឌនេះ។ ជារួម កត្តាហានិភ័យធំៗចំនួន ៣ ត្រូវបានកំណត់ដូចខាងក្រោម៖

(១).**កម្រិតនៃការយល់ដឹងអំពីបច្ចេកវិទ្យាព័ត៌មាន ៖** កម្រិតនៃការយល់ដឹងអំពីបច្ចេកវិទ្យាព័ត៌មានជាបញ្ហាប្រឈមចំបងទាំងក្នុងការរៀបចំសំណើគម្រោងមួយស្របតាមតម្រូវការចាំបាច់ និងក្នុងពេលប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ការណ៍នេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្លាំងក្នុងការបណ្តុះបណ្តាលជំនាញបច្ចេកវិទ្យាព័ត៌មានទៅដល់ភាគីពាក់ព័ន្ធ ជាពិសេសអ្នកប្រើ-ប្រាស់ ដើម្បីទាញយកគុណប្រយោជន៍ជាអតិបរមាពីការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យា។

(២). **ភាពឆ្លើយតបនៃសំណើគម្រោងនៅមានកម្រិត** (Low Compliance) ៖ ភាពស្មុគស្មាញ និងភាពប្រទាក់ក្រឡានៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានអាចបង្កឱ្យមានបញ្ហាប្រឈម ក្នុងការរៀបចំសំណើគម្រោងមួយ ជាក់លាក់ និងឆ្លើយតបតាមលក្ខខណ្ឌបច្ចេកទេសក្នុង **ក្របខណ្ឌវាយតម្លៃ**



ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

**សំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍** ។ ការណ៍នេះទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅគ្រប់ដំណាក់កាល ដើម្បីទទួលធាតុចូល និងធានាបានភាពគ្រប់ជ្រុងជ្រោយជាអតិបរមាក្នុងការរៀបចំសំណើគម្រោង។

(៣). **ផលលំបាកក្នុងការធ្វើទំនើបកម្ម និងកែប្រែប្រព័ន្ធបច្ចេកវិទ្យាដែលមានស្រាប់ ៖** ប្រព័ន្ធបច្ចេក-វិទ្យា ទំនើបថ្មីៗ ត្រូវបានអភិវឌ្ឍឡើងក្នុងគោលបំណងទាក់ទាញអ្នកប្រើប្រាស់មកក្នុងប្រព័ន្ធអេកូឡូស៊ីរបស់ខ្លួន ជាហេតុបង្កឱ្យមានភាពលំបាកក្នុងការផ្លាស់ប្តូរបច្ចេកវិទ្យា (lock-in) ដែលទាមទារឱ្យមានការចំណាយខ្ពស់ (high switching cost)។ បន្ថែមពីលើនេះ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាតជំនាន់ (legacy system) មានភាពស្មុគស្មាញក្នុងការតភ្ជាប់ និងធ្វើសន្ទាន-កម្មជាមួយប្រព័ន្ធដទៃ ដែលចាំបាច់ត្រូវមានការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយ ជាពិសេសផ្នែកបច្ចេកទេសមុនធ្វើការអភិវឌ្ឍ ដើម្បីធានាបាននូវប្រសិទ្ធភាពចំណាយរយៈពេលវែង។

## ៦. សេចក្តីសន្និដ្ឋាន

ការដាក់ចេញនូវ ក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍នេះ ត្រូវបានរំពឹងយ៉ាងមុតមាំថា នឹងរួមចំណែកៈ ១)- ជំរុញការធ្វើសុខដុមនីយកម្មគម្រោងបច្ចេកវិទ្យាព័ត៌មាននិងគមនា-គមន៍ពីគ្រប់ប្រភពហិរញ្ញប្បទាន និងគ្រប់កម្រិតរដ្ឋបាលដោយធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃចំណាយសាធារណៈតាមរយៈការវិនិយោគចំទិសដៅឆ្លើយតបនឹងតម្រូវការជាអាទិភាពទៅតាមលទ្ធភាពជាក់ស្តែងនៃថវិកា និងការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលរឹងមាំ មានសុវត្ថិភាព និងមានស្ថិរភាពខ្ពស់ ២)- លើកកម្ពស់ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព និង គណនេយ្យភាពនៃការអនុវត្តក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និង គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ព្រមទាំងគ្រប់គោលនយោបាយផ្សេងទៀត ក្នុងវិស័យឌីជីថល ដើម្បីចូលរួមចំណែកក្នុងការជំរុញ និងពន្លឿនការកសាង និងអភិវឌ្ឍរដ្ឋាភិបាល, សេដ្ឋកិច្ច, ធុរកិច្ច និង សង្គមឌីជីថល ប្រកបដោយចីរភាព, បរិយាបន្ន និង ភាពរឹងមាំ។

ដំណើរឆ្ពោះទៅកាន់បរិវត្តកម្មឌីជីថលទាមទារឱ្យមានការសម្របសម្រួលដូចគ្នានឹងការងារកែទម្រង់របស់រាជរដ្ឋាភិបាលដែលក្នុងនោះរួមមានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ផងដែរ បន្ថែមលើនេះ កត្តាហានិភ័យមួយចំនួនរួមមាន កម្រិតការយល់ដឹងអំពីបច្ចេកវិទ្យាព័ត៌មាន (Low tech knowledge in preparation), ភាពឆ្លើយតបនៃសំណើគម្រោងនៅមានកម្រិត (Low Compliance) និងផលលំបាកក្នុងការធ្វើទំនើបកម្ម និងកែប្រែប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានស្រាប់ (Lock-In/high switching cost of existing ICT system) អាចនឹងធ្វើឱ្យការអនុវត្តក្របខណ្ឌវាយតម្លៃសំណើគម្រោងនេះមិនអាចសម្រេចបានតាមគោលបំណង និងគោលដៅដែលបានរំពឹងទុក។

ក្នុងន័យនេះ, ការបង្កើនសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងការចូលរួមអនុវត្តក្របខណ្ឌវាយតម្លៃសំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និង គមនាគមន៍ប្រកបដោយគណនេយ្យភាពពីគ្រប់ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាម្ចាស់គម្រោងគឺជាកត្តាចាំបាច់បំផុត។

## ឧបសម្ព័ន្ធទី ១ ៖ ការដាក់ពិន្ទុសំណើគម្រោង

លក្ខណៈវិនិច្ឆ័យនៃការដាក់ពិន្ទុត្រូវបានជ្រើសរើស និងរៀបចំផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD Development Assistance Committee) ស្របទៅតាមទំហំ និងភាពស្មុគស្មាញនៃសំណើគម្រោង ដូចបានកំណត់ខាងក្រោម៖

**តារាងទី២៖ លក្ខណៈវិនិច្ឆ័យនៃការដាក់ពិន្ទុ**

| លក្ខណៈវិនិច្ឆ័យ | បរិយាយ | គំរូសំណួរ | ទម្ងន់ |
|---|---|---|---|
| ១ .កម្រិតភាពពាក់ព័ន្ធ (Relevance) | ពិនិត្យមើលវិសាលភាពនៃគោលបំណង និងការរៀបចំគម្រោង ឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងអាទិភាពរបស់អង្គភាព អនុលោមតាមគោលនយោបាយតាមអាទិភាពជាយុទ្ធសាស្ត្រ | ១.១. តើសំណើមានភាពសមស្របជាមួយតម្រូវការរបស់គោលនយោបាយរដ្ឋាភិបាល យុទ្ធសាស្ត្ររបស់ស្ថាប័នដែលបានដាក់ចេញកម្រិតណា? ១.២. តើមុខងារនៃសំណើមានភាពពាក់ព័ន្ធជាមួយតម្រូវការរបស់អ្នកប្រើប្រាស់បានក្នុងកម្រិតណា? | ១៥% |
| ២. កម្រិតភាពប្រទាក់ក្រឡាគ្នា (Coherence) | ពិនិត្យលើភាពទាក់ទងគ្នា (compatibility) ទៅលើទស្សនាទាននៃការរៀបចំគម្រោងដែលគិតគូរទៅលើវំហូរនៃការកសាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមមាន ៣ ដំណាក់កាល៖ (១). ការសិក្សាពីតម្រូវការក្នុងការកសាងប្រព័ន្ធ, (២). ការសិក្សាពីតម្រូវការនៃការប្រើប្រាស់ និង (៣). ការសិក្សាពីតម្រូវការនៃការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានវាស់វែងភាពទាក់ទងគ្នា រវាងសំណើ និងគម្រោងដទៃទៀតក្នុងការបង្កើតតម្លៃបន្ថែមនិងជៀងវាងការបង្កើតស្ទួន។ | ២.១. តើសំណើមានភាពប្រទាក់ក្រឡាគ្នាជាមួយគម្រោងដទៃដែរឬទេ? ហើយស្ថិតក្នុងកម្រិតណា? | ១៥% |
| ៣. ប្រសិទ្ធភាព ឬភាពសម្រេចបាន (Effectiveness) | ពិនិត្យលើលទ្ធភាពនៃភាពជោគជ័យនៃសំណើក្នុងការកំណត់លទ្ធផល និងលទ្ធផលចុងក្រោយ | ៣.១. តើកត្តាអ្វីខ្លះដែលអាចនឹងចូលរួមចំណែកក្នុងការកំណត់ភាពជោគជ័យនៃសំណើ? | ២០% |

ឯកសារមន្ត្រីសាធារណៈ | https://t.me/oa_channel

| | | | |
|---|---|---|---|
| ៤. ស័ក្តិសិទ្ធភាព (Efficiency) | ពិនិត្យលើកម្រិតនៃការប្រើប្រាស់ធនធានដើម្បីជានាបាន (Materialize) នូវគោលបំណងនៃសំណើ | ៤.១. តើធនធានដែលមាន អាចសម្រេចសំណើបានកម្រិតណាធៀបទិន្នន័យមូលដ្ឋាន និង/ឬឧត្តមានុវត្ត-ន៍? | ២០% |
| ៥. បច្ច័យ (Impact) | សំដៅដល់ការរំពឹងទុកនៃបច្ច័យដែលអាចកើតឡើងពីការអនុវត្តគម្រោង (វិជ្ជមាន, អវិជ្ជមាន, និងលទ្ធផលរយៈពេលវែង) | ៥.១. តើសំណើអាចផ្តល់បច្ច័យអ្វីខ្លះ (វិជ្ជមាន, អវិជ្ជមាន) ក្នុងករណីដែលសំណើត្រូវបានទទួលយក?<br>៥.២. តើផលប៉ះពាល់ទាំងនេះ នឹងបង្កឱ្យមានបច្ច័យរយៈពេលវែងកម្រិតណានៅក្នុងទិដ្ឋភាពសង្គម បរិស្ថាន និងសេដ្ឋកិច្ច? | ២០% |
| ៦. ចីរភាព (Sustainability) | ពិនិត្យលើលទ្ធភាពនៃការបន្តធានាបាន គុណប្រយោជន៍បន្ទាប់ពីគម្រោងបានបញ្ចប់ | ៦.១.តើសំណើនឹងអាចបង្កើតបានជាកត្តាជំរុញ (enabling environment) កម្រិតណា និង/ឬបង្កើតតម្លៃបន្ថែមក្នុងប្រព័ន្ធអេកូឡូ-ស៊ីកម្រិតណា?<br>៦.២. តើកត្តាណាខ្លះដែលអាចជះឥទ្ធិពល (វិជ្ជមាន/ អវិជ្ជមាន) ទៅលើលទ្ធផលរំពឹងទុកនៃសំណើ? | ១០% |

## តារាងទី៣ ៖ គំរូតារាងពិនិត្យ និង ផ្តល់យោបល់លើសំណើគម្រោង

ឈ្មោះគម្រោង៖____________________________________________

ម្ចាស់គម្រោង៖______________________________________

| លក្ខណៈវិនិច្ឆ័យ | ទម្ងន់ | ពិន្ទុ (០ ដល់១០០) | ពិន្ទុថ្លឹង | មតិយោបល់អ្នកវាយតម្លៃ |
|---|---|---|---|---|
| ១. កម្រិតភាពពាក់ព័ន្ធ (Relevance) | ១៥% | | | |
| ២. កម្រិតភាពប្រទាក់ក្រឡាគ្នា (Coherence) | ១៥% | | | |
| ៣. ប្រសិទ្ធភាព ឬភាពសម្រេចបាន (Effectiveness) | ២០% | | | |
| ៤. ស័ក្តិសិទ្ធភាព (Efficiency) | ២០% | | | |
| ៥. បច្ច័យ (Impact) | ២០% | | | |
| ៦.ចីរភាព (Sustainability) | ១០% | | | |
| | | ពិន្ទុសរុបរួម | | |

អ្នកវាយតម្លៃ៖_______________________________

ហត្ថលេខា៖________________________________

ឯកសារមេឡើងសាធារណៈ | https://t.me/oa_channel

## ឧបសម្ព័ន្ធទី ២ ៖ វាក្យសព្ទបច្ចេកទេស

វាក្យសព្ទបច្ចេកទេសនៅក្នុង ក្របខណ្ឌនេះមានន័យដូចតទៅ៖

- **បច្ចេកវិទ្យាព័ត៌មាន (IT) ៖** សំដៅលើការប្រើប្រាស់បញ្ចូលគ្នានូវម៉ាស៊ីនកុំព្យូទ័រ, ឧបករណ៍អេឡិចត្រូនិក, ប្រព័ន្ធ ឬ កម្មវិធីកុំព្យូទ័រ, ឧបករណ៍រក្សាទុកទិន្នន័យ, ឧបករណ៍សំឡេង ជាដើម ដែលផ្តល់ជាមធ្យោបាយក្នុងការរក្សាទុកទិន្នន័យ, ទាញយកទិន្នន័យ, ដំណើរការទិន្នន័យ, បញ្ជូន ទិន្នន័យ និងទទួលទិន្នន័យក្នុងទម្រង់ជាអេឡិចត្រូនិក ។ សមាសធាតុធំៗនៃបច្ចេកវិទ្យាព័ត៌មាន រួមមាន៖
    - **ឧបករណ៍ និង ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន** គឺជាសមាសធាតុរឹង និងជាគ្រឹះសម្រាប់ទ្រទ្រង់ដល់ដំណើរការនៃប្រព័ន្ធ និងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន ឬប្រព័ន្ធឌីជីថលនានា ដែលរួមមាន មជ្ឈមណ្ឌលទិន្នន័យ (Data Center), ម៉ាស៊ីនមេ (Server), ឧបករណ៍ ឬ ប្រព័ន្ធរក្សាទុកទិន្នន័យ (Storage), ឧបករណ៍ IT សម្រាប់អ្នកប្រើប្រាស់ (កុំព្យូទ័រ, ទូរស័ព្ទ, ឧបករណ៍ឆ្លាតវៃផ្សេងទៀតជាដើម), បណ្តាញតភ្ជាប់បច្ចេកវិទ្យាព័ត៌មាន (បណ្តាញតភ្ជាប់ផ្ទៃក្នុង និងបណ្តាញតភ្ជាប់ទូទាំងប្រទេស), បណ្តាញអ៊ីនធឺណិត ។ល។
    - **ប្រព័ន្ធ និងកម្មវិធីបច្ចេកវិទ្យាព័ត៌មាន** គឺជាសមាសធាតុទន់ ដែលដំណើរការ នៅក្នុងឧបករណ៍ IT និងធ្វើឱ្យឧបករណ៍ IT នីមួយៗមានដំណើរការអន្តរសកម្មជាមួយគ្នា ស្របតាមការបញ្ជារបស់អ្នកប្រើប្រាស់ ឬដំណើរការដោយស្វ័យប្រវត្តិ ។ ផ្អែកលើវិសាលភាព និងភាពគ្រប់គ្រាន់នៃហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន, កម្មវិធីបច្ចេកវិទ្យាព័ត៌មាន ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ជាប្រយោជន៍ក្នុងការគាំទ្រដល់ប្រតិបត្តិការការងារប្រចាំថ្ងៃ, ប្រតិបត្តិការធុរកិច្ច, ស្វ័យប្រវត្តិកម្មការងារ, ផលិតកម្ម, ការផ្តល់សេវាសាធារណៈ ជាដើម និងផ្តល់លទ្ធភាព ក្នុងការប្រើប្រាស់បានពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ។
    - **ទិន្នន័យ** គឺជាធាតុមួយដ៏ចាំបាច់បំផុតមិនអាចខ្វះបាន សម្រាប់កម្មវិធីបច្ចេកវិទ្យាព័ត៌មានក្នុងការដំណើរការ និងផលិតចេញនូវលទ្ធផលជាច្រើនតាមតម្រូវការ និងគោលបំណងរបស់អ្នកប្រើប្រាស់ ។
- **បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) ៖** សំដៅទៅលើការពង្រីកសមត្ថភាពបន្ថែមទៅលើបច្ចេកវិទ្យាព័ត៌មាន (IT) ដោយបញ្ចូលបន្ថែមនូវប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍ផ្សារភ្ជាប់នឹងការប្រើប្រាស់បណ្តាញតភ្ជាប់កុំព្យូទ័រ ។
- **សំណើគម្រោង (Project Proposal) ៖** សំដៅដល់សំណើគម្រោងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) ដែលមានចរិតលក្ខណៈជាគម្រោងរដ្ឋាភិបាលឌីជីថល និង/ឬ គម្រោងសេដ្ឋកិច្ច, ធុរកិច្ច និងសង្គមឌីជីថល ដែលស្នើឡើងដោយក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈ ឬ រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាម្ចាស់គម្រោង ។
- **ការវាយតម្លៃសំណើគម្រោង (Project Appraisal) ៖** សំដៅដល់ដំណើរការវាយតម្លៃលើទិដ្ឋភាពសំខាន់ៗនៃសំណើគម្រោងរួមមាន ៖ បច្ចេកទេស, តម្លៃ, ហានិភ័យ, ផលសេដ្ឋកិច្ច និងសង្គម, ផលប៉ះពាល់បរិស្ថាន និង សង្គម និងថវិកា ជាដើម ។

- **ការសិក្សាសមិទ្ធិលទ្ធភាព** (Feasibility Study) សំដៅដល់ការសិក្សាស៊ីជម្រៅលើសំណើគម្រោង ដោយរួមបញ្ចូលការវិភាគលើទិដ្ឋភាពពាក់ព័ន្ធ រួមមាន ៖ បច្ចេកទេស, ហានិភ័យ, សេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ច្បាប់, ផលប៉ះពាល់បរិស្ថាន និងសង្គម, ភាពអាចទ្រទ្រង់បាននៃថវិកា ព្រមទាំងយន្តការ និងសមត្ថភាពស្ថាប័ន សម្រាប់ការគ្រប់គ្រង និងតាមដានការអនុវត្តគម្រោង ដោយត្រូវគោរពតាមគោលការណ៍ណែនាំលម្អិត និងនីតិវិធីរៀបចំ និងគ្រប់គ្រងប្រតិបត្តិការ ជាធរមាន។
- **ទ្វារបាលកិច្ច** (Gatekeeping) សំដៅដល់មុខងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការ-ពិនិត្យ និងវាយតម្លៃសំណើគម្រោង, ការធ្វើអាទិភាវូបនីយកម្ម, ការជ្រើសរើស និងថវិកានីយកម្ម ព្រមទាំងការតាមដាន និង ត្រួតពិនិត្យលើការអនុវត្តគម្រោង ។
- **ឯកសារទស្សនាទានគម្រោង** (Project Concept Note) សំដៅដល់ឯកសារទស្សនាទានបឋម ដែលបញ្ជាក់អំពីសនិទានកម្ម, គោលដៅនៃគម្រោង, តម្រូវការ និងអាទិភាពនៃគម្រោង, ការផ្សារភ្ជាប់ទៅនឹងគោលនយោបាយជាតិ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឪជីថល, គោលនយោបាយតាមវិស័យ និងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀតរបស់រាជរដ្ឋាភិបាល ។

ឯកសារមេឡើងសាធារណៈ | https://t.me/oa_channel

*(+855) 87 888 608*
*digitaleconomy@mef.gov.kh*
*www.digitaleconomy.gov.kh*

អគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច (BDC), ជាន់ទី១៧, មហាវិថី OCIC,
សង្កាត់ជ្រោយចង្វារ, ខណ្ឌជ្រោយចង្វារ, រាជធានីភ្នំពេញ